សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS


## សារណាបញ្ចប់ការសិក្សា

# ឥទ្ធិពលគតិយុត្តនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លឹម មុយយីម**

**សេរី សុតារិទ្ធិ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី ២២

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លីម មុយយីម** និង **សេរី សុភារិទ្ធិ** ជានិស្សិតឆ្នាំទី៤ ថ្នាក់ L4B1 នៃ ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកអ្នកមានគុណទាំងពីរ** ដែលបានខិតខំប្រឹងប្រែង និងតស៊ូចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបទៅដោយព្រហ្មវិហារធម៌ ផ្តល់នូវការស្រឡាញ់ ទូន្មានប្រៀនប្រដៅ ដោយគ្មានខ្លាចភាពនឿយហត់ និងចង់ឃើញកូនទទួលបាននូវចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីជាស្ពានសម្រាប់អនាគតកូន និងជាធនធានសម្រាប់ប្រទេសជាតិ។ ទំហំនៃសេចក្តីស្រឡាញ់ និងការតស៊ូរបស់លោកអ្នកមានគុណទាំងពីរពុំអាចកាត់ថ្លៃបានឡើយ និងជាកាតាលីករជំរុញឆន្ទៈ និងស្មារតីរបស់កូនក្នុងការជម្នះគ្រប់ឧបសគ្គដើម្បីសម្រេចដល់គោលដៅដែលកូនចង់ប្រាថ្នា។ រាល់ពាក្យទូន្មានប្រៀនប្រដៅរបស់លោកអ្នកមានគុណ បានស្រោចស្រពដល់កូនឱ្យបានក្លាយជា កូនល្អ សិស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គម និងចេះស្គាល់ខុសត្រូវ រហូតមកដល់សព្វថ្ងៃ។ សូមថ្លែងអំណរគុណលោកទាំងពីរចំពោះការយកចិត្តទុកដាក់ និងការផ្តល់កម្លាំងចិត្តកន្លងមក។

## យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ

ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាត និងផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទនេះ និងទទួលបានការយល់ដឹងអំពីឥទ្ធិពលគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់មកលើសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

**បណ្ឌិត ហាប់ ផល្លី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ពួកខ្ញុំ ហើយលោកគ្រូបានចំណាយពេលវេលាផ្ទាល់ខ្លួនយ៉ាងមានតម្លៃក្នុងការតម្រង់ទិសដល់ក្រុមយើងខ្ញុំ ការផ្តល់យោបល់ និងការកែលម្អចំពោះចំណុចខ្វះខាតក្នុងការសរសេរសារណា។ ទោះបីជាមានជួបនូវឧបសគ្គជាច្រើនក្នុងការសរសេរ លោកគ្រូតែងតែលើកទឹកចិត្ត និងណែនាំអំពីចំណុចខ្វះខាត ដោយផ្តល់ការពន្យល់យ៉ាងក្បោះក្បាយ និងច្បាស់លាស់ដល់ក្រុមយើងខ្ញុំ។ ពួកខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដែលមានលោកគ្រូជាសាស្ត្រាចារ្យណែនាំសារណាសម្រាប់ក្រុមយើងខ្ញុំ។

ជាអវសានកថា ក្រុមយើងខ្ញុំមានតែលើកដៃសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជូនចំពោះលោកអ្នកមានគុណ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យណែនាំ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ដែលបានផ្តល់កម្លាំងចិត្ត រួមទាំងសមាជិកក្រុមក្នុងការសម្រេចនូវសារណាបញ្ចប់ការសិក្សាមួយនេះ។

# **អារម្ភកថា**

យើងខ្ញុំដែលជានិស្សិតនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំ និងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រដោយជ្រើសរើសយកនូវប្រធានបទ “**ឥទ្ធិពលគតិយុត្តនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ចកម្ពុជា**” ដើម្បីធ្វើការសិក្សាអំពីឥទ្ធិពលវិជ្ជមាន និងបញ្ហាប្រឈមនៃគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ចកម្ពុជា ដោយពិចារណាទៅលើបរិយាកាសនៃការវិនិយោគនៅកម្ពុជា និងរបបគតិយុត្តសម្រាប់គ្រប់គ្រង និងគាំពារការវិនិយោគ។

ការស្រាវជ្រាវបានពឹងផ្អែកលើការបកស្រាយ ដោយយោងលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ប្រទេសកម្ពុជា ព្រមទាំងទិន្នន័យស្រាវជ្រាវរបស់អង្គការអន្តរជាតិនានា។ ហេតុដូចនេះ ក្រុមយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការស្រាវជ្រាវនេះអាចផ្តល់ពុទ្ធិ និងការយល់ដឹងបន្ថែមពីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងសារៈសំខាន់នៃគម្រោងនេះចំពោះសេដ្ឋកិច្ចជាតិ។

យើងខ្ញុំសូមអភ័យទោសចំពោះរាល់ចំណុចខ្វះខាត និងការធ្វេសប្រហេសណាមួយដែលកើតមានឡើងដោយអចេតនា។ ជាចុងបញ្ចប់យើងខ្ញុំ សូមថ្លែងអំណរគុណដល់សំណាក់អ្នកអានទាំងអស់គ្នា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាន និងស្វែងយល់ពីគោលគំនិតរបស់យើងខ្ញុំ។ យើងខ្ញុំសូមគោរពជូនពរ និងសូមប្រសិទ្ធិពរជ័យដល់ លោកអ្នករាល់គ្នាឱ្យជួបតែសំណាងល្អ។

ធ្វើនៅថ្ងៃច័ន្ទ ១១កើត ខែស្រាពណ៍ ព.ស ២៥៦៦ ឆ្នាំខាល

ត្រូវនឹងថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០២២

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 1

៣. គោលបំណងនៃការស្រាវជ្រាវ ........ 2

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ 2

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ 2

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 3

## ជំពូកទី១
## បរិយាកាសវិនិយោគនៅកម្ពុជា

១.១. និន្នាការការវិនិយោគដោយផ្ទាល់ពីបរទេសនៅកម្ពុជា ........ 5

១.២. ធនធានមនុស្ស និងកម្លាំងពលកម្ម ........ 7

១.៣. ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ការវិនិយោគ ........ 10

១.៣.១. ការកសាងសង្គមឌីជីថល ........ 10

១.៣.២. ការកសាងស្ពាន និងផ្លូវថ្នល់ ........ 11

១.៣.៣. ការផ្គត់ផ្គង់ថាមពលអគ្គិសនី ........ 12

១.៤. កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងប្រព័ន្ធអនុគ្រោះពន្ធ ........ 12

១.៥. ប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងការវិនិយោគ ........ 15

## ជំពូកទី២
## របបគតិយុត្តនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

២.១. សញ្ញាណទូទៅនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 18

២.១.១. និយមន័យ និងប្រភេទនៃគម្រោងវិនិយោគ ........ 18

២.១.២. អង្គភាពទទួលបន្ទុកការវិនិយោគ ........ 18

២.១.២.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........ 18

២.១.២.២. អនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត ........ 20
២.១.៣. ការលើកទឹកចិត្តចំពោះការវិនិយោគ ........ 21
២.១.៣.១. ការលើកទឹកចិត្តជាមូលដ្ឋាន ........ 21
២.១.៣.២. ការលើកទឹកចិត្តបន្ថែម ........ 23
២.១.៤. ការធានាលើការវិនិយោគ ........ 23
២.១.៥. សកម្មភាពវិនិយោគ និងវិស័យហាមឃាត់ ........ 24
២.២. នីតិវិធីចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 25
២.២.១. យុត្តាធិការនៃការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 25
២.២.២. នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 26
២.២.១.១. ការដាក់ពាក្យស្នើសុំ ........ 26
២.២.១.២. ការអនុញ្ញាត ឬការបដិសេធការចុះបញ្ជី ........ 28
២.២.១.៣. ការចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរនិងការចាប់ផ្ដើមគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់..... 29
២.២.៣. កាតព្វកិច្ចរាយការណ៍ស្ដីពីពន្ធដារ និងពន្ធគយ ........ 30
២.២.៤. កាតព្វកិច្ចស្នើសុំការយល់ព្រមផ្សេងៗរបស់ម្ចាស់គម្រោងវិនិយោគ ........ 30
២.២.៥. ការដកហូតគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 31
២.៣. ទម្រង់សម្ព័ន្ធអាជីវកម្មនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 32
២.៣.១. ការរំលាយចូលគ្នានៃគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 32
២.៣.២. ការទិញយកគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ........ 32

## ជំពូកទី៣

## ឥទ្ធិពល និងផលជះនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ចកម្ពុជា

៣.១. គុណសម្បត្តិ ........ 34
៣.១.១. វិស័យកសិកម្ម ........ 34
៣.១.២. វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ........ 35
៣.១.៣. វិស័យទេសចរណ៍ ........ 37
៣.១.៤. វិស័យសំណង់ ........ 38
៣.២. បញ្ហាប្រឈម ........ 39

**សេចក្តីសន្និដ្ឋាន** ........................................................................................................ 43
**អនុសាសន៍** ................................................................................................................ 44
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីក្រាហ្វិក

ទំព័រ

ក្រាហ្វិកទី១៖ ការវិនិយោគដោយផ្ទាល់នៅកម្ពុជា (ឆ្នាំ២០១៥-២០២១)........................................6
ក្រាហ្វិកទី២៖ ការវិនិយោគទៅតាមវិស័យ.........................................................................7
ក្រាហ្វិកទី៣៖ កម្លាំងពលកម្មតាមវិស័យ និងប្រភេទការងារ.........................................................8
ក្រាហ្វិកទី៤៖ ការសង្ខេបនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ...............29

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីឆ្លងកាត់ភ្លើងសង្គ្រាមអស់ជាច្រើនទសវត្សរ៍មក ប្រទេសកម្ពុជាតាមរយៈជំនួយរបស់អង្គការសហប្រជាជាតិ កម្ពុជាបានចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដើម្បីបញ្ចប់សង្គ្រាមស៊ីវិល និងធ្វើការបោះឆ្នោតដើម្បីជ្រើសរើសតំណាងរាស្ត្រសម្រាប់ដឹកនាំប្រទេសសារជាថ្មី។ តាមរយៈនេះ កម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលបានធ្វើកំណែទម្រង់ពីប្រព័ន្ធសេដ្ឋកិច្ចផែនការ មកជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលជាចំណុចចាប់ផ្តើមមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ ដោយសម្លឹងឃើញពីសារៈសំខាន់នៃការវិនិយោគដោយផ្ទាល់ដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ហេតុនេះហើយទើបរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអភិវឌ្ឍបរិយាកាសវិនិយោគនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ជាពិសេសទៅលើ វិស័យគមនាគមន៍ និងដឹកជញ្ជូន វិស័យអប់រំ ប្រព័ន្ធទឹក អគ្គិសនីជាអាទិ៍។ ម្យ៉ាងវិញទៀត ក្នុងនាមជាប្រទេសស្ថិតក្រោមបន្ទាត់ភាពក្រីក្រ កម្ពុជាទទួលបានការលើកទឹកចិត្ត និងលើកលែងពន្ធជាច្រើនពីបណ្តាប្រទេសមហាអំណាចលោកខាងលិច។ កត្តាខាងលើ បូករួមទាំងតម្លៃទាបនៃកម្លាំងពលកម្មនៅកម្ពុជា គឺជាចំណុច ដែលទាក់ទាញដល់ការវិនិយោគពីបរទេស។

បន្ថែមពីលើបរិយាកាសវិនិយោគដែលល្អប្រសើរ យន្តការក្នុងការគ្រប់គ្រង និងគាំពារការវិនិយោគក៏មានសារៈសំខាន់ផងដែរក្នុងការផ្តល់ទំនុកចិត្តដល់វិនិយោគិន។ ហេតុដូច្នេះទើបរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការវិនិយោគ ជាពិសេសនៅឆ្នាំ ២០២១ កន្លងទៅនេះ រាជរដ្ឋាភិបាលបានអនុម័តច្បាប់វិនិយោគថ្មី សំដៅលើកទឹកចិត្ត ផ្តល់ការការពារ និងការធានាបន្ថែមដល់គម្រោងវិនិយោគទាំងអស់ដោយពុំមានការរើសអើងរវាងវិនិយោគិនជាតិ ឬបរទេសឡើយ។

គម្រោងវិនិយោគមួយផ្នែកធំនៅកម្ពុជាបច្ចុប្បន្នផ្តោតសំខាន់ទៅលើតែវិស័យធំៗមួយចំនួនដូចជា វិស័យកាត់ដេរ និងសម្លៀកបំពាក់ វិស័យទេសចរណ៍ និងវិស័យសំណង់ ដែលវិស័យទាំងបីបានបង្កើតការងារធ្វើ លើកស្ទួយជីវភាពប្រជាជន និងបង្កើតប្រាក់ចំណូលសម្រាប់ជាតិ។ យ៉ាងណាមិញ លក្ខណតូចចង្អៀតនៃវិស័យស្នូលសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច នាំឱ្យកម្ពុជាងាយទទួលរងនូវឥទ្ធិពលអវិជ្ជមានពីការថយចុះនៃតម្រូវការទីផ្សារពិភពលោក។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុថាកម្ពុជាទទួលបានសម្ទុះរីកចម្រើនយ៉ាងឆាប់រហ័សពីការវិនិយោគដោយផ្ទាល់ពីបរទេស ដូច្នេះហើយទើបមានការចោទជាសំណួរឡើងថា៖

- តើបរិយាកាសវិនិយោគនៅកម្ពុជាបច្ចុប្បន្នមានលក្ខណៈយ៉ាងដូចម្ដេច?
- តើរបបគតិយុត្តសម្រាប់គ្រប់គ្រង និងគាំពារគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅកម្ពុជាមានលក្ខណៈយ៉ាងដូចម្ដេចខ្លះ?
- តើគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានផ្ដល់ឥទ្ធិពលវិជ្ជមាន និងបញ្ហាប្រឈមអ្វីខ្លះដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការជ្រើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវគឺ ដើម្បីបង្ហាញអំពីសារៈសំខាន់នៃគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ចំពោះកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្រោយពីមានលំហូរវិនិយោគដោយផ្ទាល់ពីបរទេសចូលមកកម្ពុជាជាច្រើនចាប់តាំងពីឆ្នាំ ២០០០ កន្លងមក។ ព្រមទាំងជាការពិនិត្យទៅលើកាលានុវត្តភាព និងបញ្ហាប្រឈមជុំវិញបរិយាកាសវិនិយោគនៅកម្ពុជា ក៏ដូចជាប្រសិទ្ធភាពនៃរបបគតិយុត្តនៅកម្ពុជាក្នុងការទាក់ទាញវិនិយោគពីបរទេស។ កត្តាខាងលើ ជាមូលដ្ឋានសំខាន់ក្នុងការពង្រឹងគោលនយោបាយ និងដាក់ចេញយន្តការដែលត្រឹមត្រូវសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយហេតុថាគម្រោងវិនិយោគក្រោមបទដ្ឋានគតិយុត្តនៅកម្ពុជាមានច្រើនប្រភេទ ការសិក្សាស្រាវជ្រាវនេះជ្រើសយកតែគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់យកមកសិក្សា។ ម៉្យាងវិញទៀត វិស័យដែលបម្រើដល់សេដ្ឋកិច្ចកម្ពុជាមានអនុវិស័យជាច្រើនទៀត ប៉ុន្តែការសិក្សានេះក៏ផ្ដោតសំខាន់ទៅលើតែឥទ្ធិពលវិជ្ជមាន និងបញ្ហាប្រឈមដែលបានជួបប្រទះនៅក្នុងវិស័យកសិកម្ម វិស័យកាត់ដេរសម្លៀកបំពាក់ វិស័យទេសចរណ៍ និងវិស័យសំណង់ប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

- ធ្វើការវិភាគលើឯកសារច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ព្រមទាំងឯកសារចងក្រងដោយក្រសួងនានានៅកម្ពុជា
- ប្រមូលផ្តុំទិន្នន័យពីរបាយការណ៍ និងការស្រាវជ្រាវជាភាសាបរទេសរបស់អង្គការអន្តរជាតិដែលបានធ្វើការវិភាគលើសេដ្ឋកិច្ចកម្ពុជា
- ប្រើប្រាស់ប្រភពព័ត៌មាន និងឯកសារវិភាគតាមប្រព័ន្ធអនឡាញ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះត្រូវបានចែកចេញជា ៣ ជំពូក។ ជាដំបូង ជំពូកទី១ បកស្រាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា។ បន្ទាប់មក ជំពូកទី២ សិក្សាអំពីរបបគតិយុត្តនៃគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ជាចុងក្រោយ ជំពូកទី៣ ធ្វើការលើកឡើងអំពីឥទ្ធិពល និងផលជះនៃគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ទៅលើសេដ្ឋកិច្ចកម្ពុជា។

# ជំពូកទី១
# បរិយាកាសវិនិយោគនៅកម្ពុជា

# ជំពូកទី១ បរិយាកាសវិនិយោគនៅកម្ពុជា

## ១.១. និន្នាការការវិនិយោគដោយផ្ទាល់ពីបរទេសនៅកម្ពុជា

ស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជាមានការកើនឡើងជាលំដាប់ ក្នុងអត្រាកំណើនជាមធ្យម ៩% ចាប់ពីឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០១៨។[1] មិនតែប៉ុណ្ណោះនៅក្នុងឆ្នាំ ២០១៥ ប្រទេសកម្ពុជាបានប្រែក្លាយពីប្រទេសដែលមានចំណូលទាបមកជា ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ [2] កត្តាជំរុញដ៏សំខាន់មួយនៃកំណើនសេដ្ឋកិច្ចកម្ពុជាគឺ ការវិនិយោគដោយផ្ទាល់ពីបរទេស។ ប្រទេសកម្ពុជាចាប់ផ្ដើមទទួលបានលំហូរការវិនិយោគដោយផ្ទាល់យ៉ាងច្រើនចាប់តាំងពីដើមឆ្នាំ ២០០០ ដែលជាសមិទ្ធផលនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល បូករួមទាំងការអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី និងស្ថេរភាពនយោបាយនៅក្នុងប្រទេស។[3] កត្តាខាងលើ បានបង្កើតបរិយាកាសវិនិយោគយ៉ាងល្អក្នុងការទាក់ទាញការវិនិយោគពីបរទេស។[4]

លំហូរនៃការវិនិយោគដោយផ្ទាល់ពីបរទេសមានការកើនឡើងជាបន្តបន្ទាប់ក្នុងអំឡុងឆ្នាំ ២០១៥ ដល់ ២០២០។[5] ក្នុងឆ្នាំ ២០១៥ កម្ពុជាទទួលបានការវិនិយោគដោយផ្ទាល់ពីបរទេសប្រមាណជា ១,៨២៣ លានដុល្លារអាមេរិក និងមានការកើនឡើងដល់ ២,៤៧៦ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៦។[6] សម្រាប់ឆ្នាំ ២០១៧ ទឹកប្រាក់នៃការវិនិយោគពុំមានការប្រែប្រួលខ្លាំងដែលរក្សាលំនឹងនៅប្រមាណជា ២,៧៨៦ លានដុល្លារអាមេរិក។[7] ដោយឡែកក្នុង ឆ្នាំ ២០១៨ ទឹកប្រាក់នៃការវិនិយោគកើនឡើងដល់ទៅ ៣,២០៨ លានដុល្លារអាមេរិក[8] និងបន្ត

---

[1] Asian Development Bank, ADB's New 5-Year Country Strategy Supports Economic Diversification, Inclusive Growth in Cambodia [យុទ្ធសាស្ត្រប្រទេស រយៈពេល ៥ ឆ្នាំ របស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការគាំទ្រការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកំណើន] អាចរកបាននៅ https://www.adb.org/news/adbs-new-5-year-country-strategy-supports-economic-diversification-inclusive-growth-cambodia (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២២)។

[2] ធនាគារពិភពលោក, កម្ពុជារក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នា, អាចរកបាននៅ https://www.worldbank.org/km/country/cambodia/publication/Cambodia-Systematic-Country-Diagnostics (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២២)។

[3] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ការវិនិយោគ (២០២១), អាចរកបាននៅ https://opendevelopmentcambodia.net/km/topics/investment/ (ទស្សនាចុងក្រោយថ្ងៃទី ១៦ ឧសភា ២០២២)។

[4] ដដែល។

[5] UNCTAD, *World Investment Report 2021* [របាយការណ៍វិនិយោគពិភពលោកឆ្នាំ២០២១] (New York: United Nations Publications, 2021), 249។

[6] ដដែល។

[7] ដដែល។

[8] ដដែល។

កើនឡើងរហូតដល់ចំនួន ៣,៦៦២ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩។[9] ប៉ុន្តែការវិនិយោគបានធ្លាក់ចុះមកសល់ត្រឹមចំនួន ៣,៦២៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០ ដោយសារតែការរីករាលដាលនៃជម្ងឺកូវីដ-១៩។[10] គិតត្រឹមឆ្នាំ ២០២១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអះអាងថា កម្ពុជាទទួលបានការវិនិយោគក្នុងទឹកប្រាក់ប្រមាណជា ៤,៣៥ ពាន់លានដុល្លារអាមេរិក។[11] ក្រាហ្វិកខាងក្រោម បង្ហាញអំពីតម្លៃនៃការវិនិយោគនៅកម្ពុជាចាប់ពីឆ្នាំ ២០១៥ ដល់ ២០២១។




*ប្រភព៖ របាយការណ៍វិនិយោគពិភពលោកឆ្នាំ ២០២១ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

វិស័យសំខាន់ៗដែលទទួលបានការចាប់អារម្មណ៍ និងការវិនិយោគច្រើនជាងគេរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។[12] នៅក្នុងឆ្នាំ ២០១៤ វិស័យឧស្សាហកម្មទទួលបានការវិនិយោគលើសគេ ដែលមានរហូតដល់ ៧២% ឯវិស័យបន្តបន្ទាប់គឺ វិស័យទេសចរណ៍ដែលមានចំនួន ១៣% វិស័យហេដ្ឋារចនាសម្ព័ន្ធចំនួន ៨% និង វិស័យកសិកម្មចំនួន ៧%។[13] យ៉ាងណាមិញ ការវិនិយោគលើវិស័យឧស្សាហកម្មបានធ្លាក់ចុះស្ទើតែពាក់កណ្តាលនៅសល់ត្រឹម ៣៣% ប៉ុណ្ណោះ នៅអំឡុងឆ្នាំ ២០១៤ ដល់ ២០១៨ ដែលត្រូវបានជំនួសដោយ ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងចំនួន ៣២% និង វិស័យទេសចរណ៍ក្នុង

---

[9] UNCTAD, *World Investment Report 2021* [របាយការណ៍វិនិយោគពិភពលោកឆ្នាំ២០២១] (New York: United Nations Publications, 2021), 249។

[10] ដដែល។

[11] ខ្មែរថាមស៍, កម្ពុជាទាក់ទាញការវិនិយោគចំនួន ៤.៣៥ ពាន់លានដុល្លារក្នុងឆ្នាំ២០២១, អាចរកបាននៅ https://bit.ly/3p14gBa (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២២)។

[12] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ការវិនិយោគ (២០២១)។ អាចរកបាននៅ https://opendevelopmentcambodia.net/km/topics/investment/ (ចូលទស្សនាថ្ងៃទី១៦ ឧសភា ២០២២)។

[13] Sar, Senera, *A Snapshot on Investment Climate & Regulatory Framework for Investment in Cambodia* [រូបភាពនៃបរិយាកាសវិនិយោគ និងបទដ្ឋានគតិយុត្តគ្រប់គ្រងការវិនិយោគនៅកម្ពុជា] (Phnom Penh: CDC, 2019), 5។

ចំនួន ២៧%។[14] សម្រាប់វិស័យកសិកម្មវិញ គឺពុំមានការប្រែប្រួលខ្លាំងឡើយដែលទទួលបានកំណើនពី ៧% ទៅ ៨%។[15] គិតត្រឹមឆ្នាំ ២០១៩ វិស័យទេសចរណ៍ទទួលបានការវិនិយោគច្រើនជាងគេបង្អស់រហូតទៅដល់ ៦៩% ចំណែកឯវិស័យឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធវិញ មានការធ្លាក់ចុះមកនៅសល់ត្រឹម ២០% និង ៩%។[16] ជាមួយគ្នានេះដែរ វិស័យកសិកម្មក៏មានថយចុះយ៉ាងខ្លាំងផងដែរគឺនៅសល់ត្រឹមតែ ១% ប៉ុណ្ណោះ។[17] នេះសរបញ្ជាក់ឱ្យឃើញថា កម្ពុជាបានធ្វើទំនើបកម្មសេដ្ឋកិច្ច ដោយងាកចេញពីមូលដ្ឋានសេដ្ឋកិច្ចបុរាណដែលពឹងផ្អែកច្រើនលើវិស័យកសិកម្ម មកជាការអភិវឌ្ឍលើវិស័យឧស្សាហកម្ម សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ក្រាហ្វិកខាងក្រោម បង្ហាញពីការវិនិយោគនៅកម្ពុជាទៅតាមវិស័យនីមួយៗចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៩។




| | កសិកម្ម | ឧស្សាហកម្ម | ទេសចរណ៍ | ហេដ្ឋារចនាសម្ព័ន្ធ |
|---|---|---|---|---|
| 2014 | 7% | 72% | 13% | 8% |
| 2014-2018 | 8% | 33% | 27% | 32% |
| 2019 | 1% | 20% | 69% | 9% |

*ប្រភព៖ រូបភាពនៃបរិយាកាសវិនិយោគ និងបទដ្ឋានគតិយុត្តគ្រប់គ្រងការវិនិយោគនៅកម្ពុជា*

## ១.២. ធនធានមនុស្ស និងកម្លាំងពលកម្ម

កម្លាំងពលកម្មកម្ពុជាមានភាពសកម្មយ៉ាងខ្លាំង សំបូរទៅដោយយុវជនវ័យក្មេងច្រើន ដែលប្រជាជនស្ថិតក្នុងអាយុធ្វើការ (ចន្លោះអាយុចាប់ពី ១៥ ទៅ ៦៤ ឆ្នាំ) មានចំនួន ១១.៥ លាននាក់ ស្មើនឹង ៧៣.២% នៃប្រជាជនសរុប ប្រមាណជា ១៥,៣ លាននាក់។[18] ក្នុងចំណោមនោះមានភេទស្រីចំនួន ៦,១ លាននាក់ ស្មើនឹង

[14] Sar, Senera, *A Snapshot on Investment Climate & Regulatory Framework for Investment in Cambodia* [រូបភាពនៃបរិយាកាសវិនិយោគ និងបទដ្ឋានគតិយុត្តគ្រប់គ្រងការវិនិយោគនៅកម្ពុជា] (Phnom Penh: CDC, 2019), 5។

[15] ដដែល។

[16] ដដែល។

[17] ដដែល។

[18] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, *របាយការណ៍ស្តីពីអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩* (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៩), ២១។

៥៣,១% និង ភេទប្រុសចំនួន ៥,៤ លាននាក់ស្មើនឹង ៤៦,៩%។[19] ជាហេតុនាំឱ្យ អត្រាចូលរួមក្នុងពលកម្មនៃប្រជាជនក្នុងអាយុធ្វើការមានកម្រិតខ្ពស់ ដោយមានការប៉ាន់ស្មានថា មានប្រមាណជា ៦៩,៣% នៃប្រជាជនសរុប។[20]

របាយនៃកម្លាំងពលកម្មទៅតាមវិស័យ និងប្រភេទការងារនៅមានលក្ខណៈសាមញ្ញ ដោយប្រជាជនភាគច្រើននៅប្រកបរបរជា កសិករ រុក្ខប្រមាញ់ និងអ្នកនេសាទ ដែលតំណាងឱ្យ ៥៣% នៃកម្លាំងពលកម្មសរុប។[21] ក្រៅពីនេះ កម្លាំងពលកម្មច្រើនប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម និងលក់ដូរដែលមានចំនួន ១៣% និងសិប្បកម្មក្នុងចំនួន ១៧%។ អត្រានៃបុគ្គលិករោងចក្រ ម៉ាស៊ីន និងអ្នកប្រមូលផ្តុំមានចំនួន ២% ឯកម្មករមានចំនួន ៦%។ ចំពោះកម្លាំងពលកម្មជំនាញគឺមានតិចតួចបំផុត ដែលធនធានអ្នកគ្រប់គ្រងមានតែ ១% ប៉ុណ្ណោះ។ ចំណែកអ្នកមានជំនាញដទៃទៀតមាន ៤% អ្នកបច្ចេកទេស និងកម្មករមានជំនាញចំនួន ១% និងបុគ្គលិករដ្ឋបាលមានចំនួន ៣%។




*ប្រភព៖ ជំរឿនទូទៅប្រជាជនព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*

ទិន្នន័យខាងលើបង្ហាញថា ទីផ្សារការងារនៅកម្ពុជាកង្វះខាតកម្លាំងពលកម្មជំនាញ ដែលទាមទារឱ្យមានការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈបន្ថែម ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងវិស័យឯកជន និងទាក់ទាញការវិនិយោគបន្ថែម។ ជាក់ស្តែង កាលពីខែមីនា ឆ្នាំ២០២២ កន្លងទៅ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា កម្ពុជាកំពុងតែខ្វះខាតធនធានសម្រាប់បម្រើដល់ឧស្សាហកម្មកម្មន្តសាលធនស្រាល និង

[19] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, *របាយការណ៍ស្ដីពីអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩* (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៩), ២១។

[20] ដដែល, ២៤។

[21] ដដែល, ៨២។

ធនធ្ងន់នៅក្នុងស្រុក ជាពិសេសទៅលើផលិតកម្មគ្រឿងយន្ត បរិក្ខារអគ្គិសនី និងគ្រឿងបន្លាស់យានយន្ត។[22] នេះបង្ហាញថា គម្លាតជំនាញពលកម្មនៅតែជាបញ្ហាប្រឈមមួយយ៉ាងសំខាន់ សម្រាប់ទីផ្សារពលកម្មនៅកម្ពុជា។ រាជរដ្ឋាភិបាលចាំបាច់ត្រូវស្វែងរកដំណោះស្រាយលើបញ្ហាធនធានមនុស្ស ទើបកម្ពុជាអាចមានលទ្ធភាពទៅប្រកួតប្រជែងនឹងប្រទេសដទៃ ក្នុងសេដ្ឋកិច្ចទីផ្សារតំបន់ និងទីផ្សារសកល។

គន្លឹះក្នុងការអភិវឌ្ឍធនធានមនុស្សគឺ ការពង្រឹងគុណភាព និងស្តង់ដារនៃការអប់រំ។[23] របាយការណ៍របស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០១៩-២០២០ បានបង្ហាញថា កម្រិតអប់រំនៃកម្លាំងពលកម្មទាំងពីរភេទនៅកម្ពុជាមានអត្រាទាបនៅឡើយ។[24] ក្នុងចំណោមអ្នកចូលរួមពលកម្មសរុប មាន ២៦,៤% បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា ៧,២% បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា និង ៧,៤% បានបញ្ចប់ការអប់រំក្រោយមធ្យមសិក្សា ៧,៤%។[25] ដើម្បីឆ្លើយតបទៅនឹងតម្រូវពលកម្មជំនាញ រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សដោយដាក់ចេញនូវ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ ២០១៥-២០២៥។ គោលនយោបាយនេះសំដៅ បង្កើនឱកាសការងារសមរម្យដល់ប្រជាពលរដ្ឋ លើកកម្ពស់ផលិតភាពការងារ និងពង្រឹងទីផ្សារ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ស្របទៅតាមការផ្លាស់ប្តូរនៃបរិបទសេដ្ឋកិច្ចជាតិ តំបន់ និងសកលលោក។[26] នៅក្នុងផែនការអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើនដូចជា ការរៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីផ្តល់ជំនាញកម្រិតខ្ពស់ ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកផ្តល់សេវាអប់រំទៅនឹងវិស័យឯកជនដើម្បីកាត់បន្ថយគម្លាតនៃតម្រូវការជំនាញ។[27] ក្រៅពីនេះក៏មានការលើកទឹកចិត្តបន្ថែមក្នុងការសិក្សាតាមរយៈការផ្តល់ឱកាសការងារ ហាត់ការ និងការហ្វឹកហ្វឺនសម្រាប់កម្មករនិយោជិតនិងកូនជាង។[28] រាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ផងដែរទៅលើ ការពង្រឹង និងពង្រីកការអភិវឌ្ឍជំនាញទន់ ដោយមានការបន្ថែម និងបញ្ច្រាបចំណេះជំនាញទន់ក្នុងកម្មវិធីសិក្សានៅកម្រិតថ្នាក់

[22] Soth, Koemsoeun, Skilled workforce needed for business expansion [តម្រូវការពលកម្មជំនាញដើម្បីពង្រីកធុរកិច្ច] (Khmer Times, 2022) អាចរកបាននៅ https://www.khmertimeskh.com/501034697/skilled-workforce-needed-for-business-expansion/ (ទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)។

[23] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham), ២៧។

[24] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, *របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០២០* (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ), ១០៩។

[25] ដដែល។

[26] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ គណៈរដ្ឋមន្ត្រី, ២០១៥), ២។

[27] ដដែល, ១១។

[28] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ គណៈរដ្ឋមន្ត្រី, ២០១៥), ២។

មធ្យមសិក្សា ចំណេះដឹងចំពោះការអប់រំលើជំនាញបច្ចេកទេស វិជ្ជាជីវៈ និងសហគ្រិនភាព ព្រមទាំងការបន្ថែមវគ្គបណ្ដុះបណ្ដាលខ្លីៗអំពីជំនាញទន់ជូនដល់ សិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិតផងដែរ។[29] ជារួមមក រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាកង្វះខាតកម្លាំងពលកម្មជំនាញ ដើម្បីផ្សាភ្ជាប់ទីផ្សារការងារទៅនឹងតម្រូវការនៃគម្រោងវិនិយោគនៅកម្ពុជា។

## ១.៣. ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ការវិនិយោគ

ថ្វីបើការអភិវឌ្ឍលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ គឺជាគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលក្ដី យន្តការអនុវត្តជាក់ស្ដែងនៅមានគម្លាត និងភាពខ្វះចន្លោះជាច្រើន។[30] គម្រោងវិនិយោគជាច្រើននៅតែជួបឧបសគ្គ ជុំវិញបញ្ហាប្រព័ន្ធដឹកជញ្ជូនដោយសារបញ្ហាផ្លូវថ្នល់ និងតម្លៃថាមពលខ្ពស់ ជាពិសេសនៅតាមទីជនបទ ដោយសារការអភិវឌ្ឍភាគច្រើនប្រមូលផ្ដុំនៅតែទីក្រុង។[31] ដើម្បីជំរុញកំណើនវិនិយោគ និងធ្វើឱ្យកាន់តែប្រសើរដល់ការទ្រទ្រង់វិស័យវិនិយោគ កម្ពុជាចាំបាច់ត្រូវការកសាងនូវហេដ្ឋារចនាសម្ព័ន្ធអាទិភាពមួយចំនួនដូចជា (**១.៣.១**) ការកសាងសង្គមឌីជីថល (**១.៣.២.**) ការកសាងស្ពាន និងផ្លូវថ្នល់ និង (**១.៣.៣.**) ការផ្គត់ផ្គង់ថាមពលអគ្គិសនី។

### ១.៣.១. ការកសាងសង្គមឌីជីថល

មកទល់ពេលបច្ចុប្បន្ន ប្រព័ន្ធបច្ចេកវិទ្យា និងគមនាគមន៍នៅប្រទេសកម្ពុជា មានការជឿនលឿនគួរឱ្យកត់សម្គាល់។[32] ទោះជាយ៉ាងនេះក្ដី កម្ពុជានៅតែកំពុងជួបប្រទះនឹងបញ្ហាកង្វះខាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់វិស័យឌីជីថល ជំនឿទុកចិត្តពីអ្នកប្រើប្រាស់ ការយល់ដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យា ជំនាញ បច្ចេកទេស និងភាពជាអ្នកដឹកនាំក្នុងផ្នែកឌីជីថល។[33] រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយច្បាស់លាស់មួយ គឺ "ការកសាង សេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបដិវត្តកម្ម ឌីជីថលនៅក្នុងគ្រប់តួអង្គសង្គមទាំងអស់ ដូចជារដ្ឋ ធុរជន ប្រជាពលរដ្ឋដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ច"។[34] ក្នុងបរិបទឧស្សាហកម្ម ៤.០ និងបរិវត្តកម្មឌីជីផល កម្ពុជាត្រូវតែពង្រឹងខ្លួនផ្នែកបច្ចេកវិទ្យាគមនាគមន៍ ដើម្បីបង្កើននូវប្រសិទ្ធភាពក្នុងការអភិវឌ្ឍប្រទេស និងកសាងសេដ្ឋកិច្ចក៏ដូចជាទាក់ទាញការ

---

[29] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥* (ភ្នំពេញ៖ គណៈរដ្ឋមន្ត្រី, ២០១៥), ២៣។

[30] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham), 27។

[31] ដដែល។

[32] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌ និងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥* (រាជរដ្ឋាភិបាល, ២០២១), viii។

[33] ដដែល។

[34] ដដែល, ១៥, ១៧, និង ១៩។

វិនិយោគនៅកម្ពុជាឱ្យកាន់តែប្រសើរ។ ហេតុដូច្នេះ កម្ពុជាត្រូវផ្ដោតលើធាតុសំខាន់ៗដូចជា (១) មូលដ្ឋានឌីជីថលសំដៅដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល (២) ក្របខណ្ឌច្បាប់ដើម្បីបង្កើននូវភាពជឿជាក់ដល់ការប្រើប្រាស់ ទំនិញ និងសេវាឌីជីថល និងការធ្វើធុរកិច្ចឌីជីថល និងគ្រប់គ្រងសន្តិសុខសាយប័រ (៣) មូលធនមនុស្ស ដែលសំដៅដល់ការសាបព្រោះចំណេះដឹងផ្នែកឌីជីថល (៤) ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសាធារណៈ និង (៥) ការជំរុញដល់ការធ្វើធុរកិច្ចឌីជីថល។[35] ដើម្បីឱ្យមានប្រសិទ្ធភាពដល់ការអនុវត្តនៃវិស័យឌីជីថល រដ្ឋាភិបាលត្រូវតែដាក់ចេញនូវយន្តការអនុវត្ត សម្របសម្រួល តាមដាន និងវាយតម្លៃ។ យោងតាមក្របខណ្ឌ គោលនយោបាយ សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ រដ្ឋាភិបាលបានបង្កើតនូវក្រុមប្រឹក្សាជាតិ និងសេដ្ឋកិច្ច និងសង្គមឌីជីថលដែលមានគណៈកម្មាធិការជំនាញចំនួន ៣ ក្នុងការអនុវត្តដែលរួមមានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។[36]

### ១.៣.២. ការកសាងស្ពាន និងផ្លូវថ្នល់

បច្ចុប្បន្ននេះកម្ពុជាបានពង្រឹងសមត្ថភាពនៃបណ្ដាញផ្លូវដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់ខ្លួន ក៏ដូចជាជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន និងបណ្ដាប្រទេសមហាអនុតំបន់ទន្លេមេគង្គ។[37] ការសាងសង់បណ្ដាញផ្លូវល្បឿនលឿន ជាកត្តាដ៏ធំជាងគេសម្រាប់ពង្រឹងសមត្ថភាពបណ្ដាញផ្លូវនៅកម្ពុជា ព្រោះផ្លូវល្បឿនលឿនអាចបម្រើដល់សេវាកម្មដឹកជញ្ជូនបានល្អជាងផ្លូវធម្មតា និងត្រូវបានគេចាត់ទុកថាជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់វិស័យឧស្សាហកម្មទំនើបៗ និងសកម្មភាពដឹកជញ្ជូនធុនធ្ងន់ផងដែរដែលមានដូចជា គម្រោងសាងសង់ផ្លូវល្បឿនលឿន រាជធានីភ្នំពេញ-ខេត្តព្រះសីហនុ និង គម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត។[38] លើសពីនេះទៅទៀត ក្រសួងសាធារណៈការ និងដឹកជញ្ជូនបាននឹងកំពុងសាងសង់ផ្លូវថ្នល់ និងស្ពានជាច្រើនកន្លែងទៀត។ កម្ពុជាក៏កំពុងពង្រឹងការកែលម្អផ្លូវតាមទីជនបទចំនួន ៥៦ ខ្សែ

---

[35] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌ និងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥* (រាជរដ្ឋាភិបាល, ២០២១), ១២។

[36] ដដែល, ៥១។

[37] ក្រសួងសាធារណការ និងដឹកជញ្ជូន, *ហេដ្ឋារចនាសម្ព័ន្ធ៖ ផ្លូវល្បឿនលឿន,* អាចរកបាននៅ www.mpwt.gov.kh/_kh/public-works/expressways (ទស្សនាចុងក្រោយថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២)។

[38] ក្រសួងសាធារណការ និងដឹកជញ្ជូន, *ហេដ្ឋារចនាសម្ព័ន្ធ៖ ផ្លូវល្បឿនលឿន,* អាចរកបាននៅ www.mpwt.gov.kh/_kh/public-works/expressways (ទស្សនាចុងក្រោយថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២)។

ដែលមានចម្ងាយ ៧២៤ គីឡូម៉ែត ស្ថិតក្នុងខេត្តចំនួន ១០ គឺខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តកំពត។[39]

### ១.៣.៣. ការផ្គត់ផ្គង់ថាមពលអគ្គិសនី

ថាមពលអគ្គិសនីពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសនីមួយៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធសង្គមផ្សេងៗ ជាពិសេសទៅលើវិស័យវិនិយោគ ដែលមានភាពចាំបាច់ក្នុងការផលិត និង បង្កើនចង្វាក់ផលិតកម្មគ្រប់គ្រាន់។[40] យោងតាមគោលនយោបាយជាតិ ស្តីពីប្រសិទ្ធភាពថាមពលអគ្គិសនីនៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣ ថាមពលអគ្គិសនី គឺជាតម្រូវការមួយយ៉ាងចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ វិស័យធុរកិច្ច ពាណិជ្ជកម្ម និង ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។[41] រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ដើម្បីឱ្យមានប្រសិទ្ធភាពដល់ការផ្គត់ផ្គង់អគ្គិសនី ដោយផ្តោតលើចំណុចធំៗ ដូចជា ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅក្នុងវិស័យឧស្សាហកម្ម អគារពាណិជ្ជកម្ម ការផ្គត់ផ្គង់ថាមពលអគ្គិសនីទៅដល់អ្នកប្រើប្រាស់ចុងក្រោយដូចជា តាមទីជនបទ និងកន្លែងដាច់ស្រយាល និងការផ្គត់ផ្គង់ថាមពលអគ្គិសនីដោយប្រើប្រាស់ជីវម៉ាស។[42]

## ១.៤. កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងប្រព័ន្ធអនុគ្រោះពន្ធ

ដើម្បីជំរុញការវិនិយោគកម្ពុជាឱ្យមានមានការីកចម្រើន និងទាក់ទាញអ្នកវិនិយោគបរទេសកាន់តែច្រើន រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅអាស៊ី អឺរ៉ុប ចិន និង ប្រទេសជាដៃគូជាច្រើនដទៃទៀតតាមរយៈការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគី។

នៅក្នុងឆ្នាំ ២០២១ កម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួនបី ក្នុងនោះមានប្រទេសចិន កូរ៉េខាងត្បូង និង ជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ កម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយនឹងប្រទេសចិន។[43] កិច្ចព្រមព្រៀមនេះត្រូវបានរំពឹងថា ជាកម្លាំងចលករដ៏សំខាន់មួយក្នុងការជំរុញកំណើនពាណិជ្ជកម្ម ទំនិញ សេវាកម្ម និងការវិនិយោគឱ្យកាន់តែច្រើនជាងមុន

[39] ក្រសួងអភិវឌ្ឍន៍ជនបទ, គម្រោងកែលម្អផ្លូវជនបទដំហានទី៣ អាចរកបាននៅ https://bit.ly/3BHa76p (ទស្សនាចុងក្រោយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)។

[40] ក្រសួងឧស្សាហម្ម រ៉ែ និងថាមពល, *គោលនយោបាយ, យុទ្ធសាស្ត្រ, និងផែនការជាតិ ស្តីពីប្រសិទ្ធភាពថាមពលអគ្គសនីនៅក្នុងប្រទេសកម្ពុជា,* (រដ្ឋភិបាល, ១៦ ឧសភា ២០១៣), ១។

[41] ដដែល, ២, ៣។

[42] ដដែល, ១៣។

[43] ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន, លេខ នស/រកម/១០២១/០០៩, ០៥ តុលា ២០២១។

ដោយសារការទទួលបានទីផ្សារបន្ថែមសម្រាប់ មុខទំនិញថ្មីៗចំនួនរាប់រយមុខដែលបម្រើដល់ការនាំចេញ។ [44] ទន្ទឹមនឹងនេះ កំណើនការវិនិយោគដោយផ្ទាល់ពីបរទេសអាចនាំមកនូវ ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ និងជំនាញថ្មីៗ ដែលចូលរួមបង្កើតការងារថ្មីៗ ផ្តល់ការបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសដល់ប្រជាពលរដ្ឋកម្ពុជា។ [45] កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះក៏បានផ្តល់ការលើកលែងពន្ធគយ និងអាករទៅវិញទៅ មកលើផលិតផលជាច្រើនមុខ ក៏ដូចជាកិច្ចសម្របសម្រួលពាណិជ្ជកម្មទៅលើវិស័យផ្សេងៗដូចជា សេវាកម្ម និងវិនិយោគ តាមការព្រមព្រៀងរវាងប្រទេសទាំងពីរ។ [46] សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងប្រទេសកូរ៉េខាងត្បូងចុះនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វិញ កម្ពុជាទទួលបានការលើកលែងពន្ធគយ និងអាករទៅលើ ១០,០០០ មុខទំនិញដែលក្នុងនោះមាន សម្លៀកបំពាក់ វាយនភណ្ឌ ស្បែកជើង កាបូប គ្រឿងបន្លាស់គ្រឿងអេឡិចត្រូនិក កៅស៊ូ និងផលិតផលកសិកម្ម។[47] ក្នុងនាមជាសមាជិកអាស៊ាន កម្ពុជាក៏ជាផ្នែកមួយនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ានផងដែរ។[48] តាមរយៈការចូលរួមក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាទទួលបានផលប្រយោជន៍ដូចជា ការកាត់បន្ថយ ឬលុបចោលពន្ធគយ និងអាករចំពោះទំនិញដែលត្រូវនាំចូលទៅប្រទេសជាសមាជិកដទៃទៀត ការអនុញ្ញាតឱ្យមានលំហូរទំនិញ សេវាកម្ម និងកម្លាំងពលកម្មដោយសេរីក្នុងចំណោមប្រទេសជាសមាជិកទាំងដប់របស់អាស៊ាន។[49]

កម្ពុជាបានចុះកិច្ចព្រមព្រៀងសេរីពហុភាគីថ្នាក់តំបន់ ដែលបានចូលជាធរមានកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២[50] ដែលមានសមាជិកសរុបចំនួន ១៥ ប្រទេស ក្នុងនោះមានប្រទេសជា សមាជិកអាស៊ានចំនួន ១០ ប្រទេស និងប្រទេសអូស្រ្តាលី ចិន ជប៉ុន កូរ៉េខាងត្បូង និងណូវ៉ែលហ្សេឡង់។ [51] កិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំបំផុតទាំងក្នុងតំបន់ និងលើសកលលោកដែលមានសមាជិកភាពរបស់

[44] ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន, លេខ នស/រកម/១០២១/០០៩, ០៥ តុលា ២០២១។

[45] ដដែល។

[46] ដដែល។

[47] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham), 21។

[48] ដដែល, 50។

[49] ដដែល។

[50] ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, លេខ នស/រកម/១០២១/០១០, ០៥ តុលា ២០២១។

[51] ដដែល។

កម្ពុជាផងដែរ។[52] កិច្ចព្រមព្រៀងនេះបានផ្ដល់ផលប្រយោជន៍ជាច្រើនដល់កម្ពុជាដែលមានដូចជា ការលើកលែងពន្ធលើទំនិញជាច្រើនមុខ ជាពិសេសចំពោះទំនិញកសិកម្ម កសិកម្មកែច្នៃ និងឧស្សាហកម្មជាដើម។[53] ប្រទេសកម្ពុជាក្នុងនាមជាសមាជិកអាស៊ាន ក៏បានចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងបណ្ដាប្រទេសផ្សេងៗរួមមាន ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងប្រទេសជាសមាជិកអាស៊ាន និងប្រទេសជប៉ុន[54] កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងកូរ៉េខាងត្បូង[55] និង តំបន់ពាណិជ្ជកម្មសេរី អាស៊ាន–អូស្ត្រាលី–ណូវ៉ែលហ្សេឡង់។[56]

កម្ពុជាក៏មានទំនាក់ទំនងជាមួយបណ្ដាប្រទេសលោកខាងលិចដូចជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងសហគមន៍អឺរ៉ុបផងដែរ។ ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ កម្ពុជាត្រូវបានចាត់ចូលក្នុងចំណោមប្រទេសដែលទទួលបានការអនុគ្រោះពន្ធក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ២០១៦។[57] ប្រព័ន្ធអនុគ្រោះពន្ធនេះជ្រោមជ្រែងដល់ការអភិវឌ្ឍវិស័យវិនិយោគនៅកម្ពុជា ដោយបានបន្ថែមគម្រោងវិនិយោគជាច្រើននៅកម្ពុជា ដោយសារមានការអនុញ្ញាតឱ្យនាំចូលប្រមាណជា ៥,០០០ មុខទំនិញទៅកាន់សហរដ្ឋអាមេរិក ដែលក្នុងនោះមានដូចជា វ៉ាលី កាបូបស្ពាយ និងកាបូបដៃ។[58] កន្លងមកកម្ពុជាក៏ធ្លាប់ទទួលបានការលើកលែងពន្ធពីសហភាពអឺរ៉ុបផងដែរ នៅក្រោមប្រព័ន្ធអនុគ្រោះទូទៅសម្រាប់ការនាំចូលគ្រប់មុខទំនិញលើកលែងតែសព្វាវុធ។ ប៉ុន្តែនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ សហភាពអឺរ៉ុបបានសម្រេចចិត្តដកហូតផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធពីកម្ពុជា ដើម្បីចាត់វិធានការទៅលើការគាបសង្កត់នយោបាយ ជាពិសេសក្រោយពីមានការរំលាយគណបក្សប្រឆាំងធំជាងគេ និងការបង្ក្រាបទៅលើប្រព័ន្ធផ្សព្វផ្សាយមួយចំនួននៅក្នុងស្រុក។[59] ការដកហូតនេះ នាំមកនូវ

[52] ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, លេខ នស/រកម/១០២១/០១០, ០៥ តុលា ២០២១។

[53] ដដែល។

[54] ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្ដីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាង ប្រទេសជាសមាជិកអាស៊ាន និងប្រទេសជប៉ុន, លេខ នស/រកម/១០០៩/០១៩, ២២ តុលា ២០០៩។

[55] ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខណ្ឌសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងសាធារណរដ្ឋកូរ៉េ, លេខ នស/រកម/១២០៧/០៣៤, ២៧ ធ្នូ ២០០៧។

[56] ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន–អូស្ត្រាលី–ណូវ៉ែល ហ្សេឡង់, លេខ នស/រកម/១០១០/០១៦, ២៦ តុលា ២០១០។

[57] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham, 2021), 25។

[58] ដដែល, 25។

[59] ជា, មុយគីម និង ចាន់ ផល្លីកា, *កម្ពុជា និងប្រព័ន្ធអនុគ្រោះពន្ធ EBA៖ តើមានផលប៉ះពាល់បែបណាខ្លះ?* (ភ្នំពេញ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា, ២០២០), ៤។

ផលប៉ះពាល់ប្រមាណជា ២០% ទៅលើផលិតផលនាំចេញរបស់កម្ពុជា ដែលក្នុងនោះរួមមានសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ និងស្ករ។[60] ទោះមានការដកហូតការអនុគ្រោះពន្ធតែមួយផ្នែកក្តី ៨០% នៃទំនិញនាំចេញរបស់កម្ពុជានៅតែទទួលបានការលើកលែងពន្ធ និងគ្មានការកម្រិតកូតាសម្រាប់ការនាំចូលទៅទីផ្សារសហភាពអឺរ៉ុប។[61] នៅទី០១ ខែមករា ឆ្នាំ២០២១ នេះដែរ ចក្រភពអង់គ្លេសបានបញ្ចូលប្រទេសកម្ពុជាទៅក្នុងប្រព័ន្ធអនុគ្រោះពន្ធរបស់ខ្លួន ដែលផ្តល់ឱកាសដល់កម្ពុជាក្នុងការនាំចូលទំនិញដោយមិនជាប់ពន្ធ និងគ្មានការកម្រិតកូតា សម្រាប់គ្រប់ទំនិញទាំងអស់លើកលែងតែអាវុធ និងគ្រាប់រំសេវ។[62] អ្នកនៅក្នុងវិស័យកាត់ដេរ វិស័យវិនិយោគ និងមន្ត្រីរដ្ឋាភិបាលបានរំពឹងថា ប្រព័ន្ធអនុគ្រោះពន្ធរបស់ចក្រភពអង់គ្លេសនឹងជួយបំពេញបន្ថែមទៅលើការបាត់បង់ទីផ្សារពីសហភាពអឺរ៉ុប និងអាចបន្តទាក់ទាញវិនិយោគបន្ថែមចូលមកកាន់កម្ពុជា។[63]

## ១.៥. ប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងការវិនិយោគ

ក្រោយពីឆ្លងកាត់ភ្លើងសង្គ្រាម និងរបបប្រល័យពូជសាសន៍ដ៏ឃោរឃៅរបស់ខ្មែរក្រហម ប្រទេសកម្ពុជាទទួលបានស្ថេរភាពនយោបាយ និងការស្តារសេដ្ឋកិច្ចឡើងវិញជាបន្តបន្ទាប់ចាប់ពីចុងទស្សវត្សរ៍ ១៩៩០ កន្លងមក។[64] ស្ថេរភាពនយោបាយ និងសន្តិភាព អនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានឱកាសក្នុងការស្តារសេដ្ឋកិច្ច និងធ្វើកំណែទម្រង់លើប្រព័ន្ធគ្រប់គ្រងស្ថាប័ន ដើម្បីពង្រឹងអភិបាលកិច្ចឡើងវិញ។[65] ចាប់ពីឆ្នាំ ២០១៧ មកដល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានកំពុងព្យាយាមដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីទាក់ទាញវិនិយោគិន និងជាយន្តការមួយសម្រាប់គ្រប់គ្រងគម្រោងវិនិយោគឱ្យបានកាន់តែប្រសើរ។ ច្បាប់ទាំងនេះមានដូចជា ច្បាប់វិនិយោគថ្មី ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ធុរកិច្ច ច្បាប់សំណង់ និងច្បាប់ស្តីពីទូរគមនាគមន៍។

ច្បាប់វិនិយោគថ្មីត្រូវបានអនុម័តនៅថ្ងៃ១៥ តុលា ២០២១ ដែលត្រូវបានបង្កើតឡើងសម្រាប់ទាក់ទាញវិនិយោគិនបរទេស និងវិនិយោគិនខ្មែរឱ្យធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា តាមរយៈការលើកទឹកចិត្ត និងការ

[60] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham, 2021), 20។

[61] ដដែល។

[62] ដដែល។

[63] ប្រាជ្ញ, សុវណ្ណារ៉ា, បទយកការណ៍! ក្រោមប្រព័ន្ធអនុគ្រោះពន្ធ GSP របស់អង់គ្លេស កម្ពុជានឹងទទួលបានប្រយោជន៍ច្រើនក្នុងការនាំចេញ (ភ្នំពេញ៖ ខ្មែរប៉ុស្តិ៍, ២០២០) អាចរកបាននៅ https://khmerpostasia.com/archives/61802 (ចូលទស្សនាថ្ងៃទី១១ មិថុនា ២០២២)។

[64] Seong, Rith, L. Cuyvers និង S. Sok, *Do Institutions Matter for Foreign Direct Investment in Cambodia* [តើស្ថាប័នមានសារៈសំខាន់ចំពោះការវិនិយោគដោយផ្ទាល់នៅកម្ពុជាឬទេ] (Centre for ASEAN Studies, 2017), 11។

[65] ដដែល។

ការពារសិទ្ធិ និងផលប្រយោជន៍នានាដល់វិនិយោគិន។[66] ទន្ទឹមនឹងនេះច្បាប់នេះមានគោលដៅ បង្កើតការប្រកួតប្រជែង បង្កើនផលិតភាពនៃឧស្សាហកម្ម ព្រមទាំងផ្តល់ការងារបច្ចេកទេសដល់ប្រជាជនកម្ពុជាផងដែរ។[67] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានអនុម័តឡើងដើម្បីគ្រប់គ្រងរាល់ប្រតិបត្តិការធុរកិច្ចតាមប្រព័ន្ធឌីជីថលក្នុងព្រះរាជាណាចក្រកម្ពុជា និងអន្តរជាតិ ដែលមានវិសាលភាពគ្របដណ្តប់លើរាល់ឯកសារ ទិន្នន័យ និងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណីដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក។[68] រាល់បុគ្គល ឬនីតិបុគ្គលណាដែលមានបំណងប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចាំបាច់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម។[69] រីឯក្នុងវិស័យធុរកិច្ចវិញមានច្បាប់ស្តីពីការប្រកួតប្រជែងដែលគ្រប់គ្រងលើសកម្មភាព រឹតត្បិត រារាំង ឬបង្ខូច ដល់ការប្រកួតប្រជែងនៅក្នុងទីផ្សារ។[70] លើសពីនេះក៏មាន ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានបង្កើតឡើង ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ក្នុងការទទួលបានទំនិញ សេវា ឬផលិតផលដែលមានគុណភាពខ្ពស់ តម្លៃថោក សម្បូរបែប និងមានជម្រើសច្រើន ក្នុងគោលដៅបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់។[71]

ដោយមើលឃើញពីសម្ទុះនៃការវិនិយោគក្នុងវិស័យសំណង់ និងអចលនទ្រព្យនៅកម្ពុជា រដ្ឋាភិបាលកម្ពុជាត្រូវបានយកចិត្តទុកដាក់គ្រប់គ្រងលើគុណភាពសំណង់ ដើម្បីការពារហានិភ័យ និងគ្រោះថ្នាក់ដល់មនុស្សជាតិ។ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាក្រសួងទទួលបន្ទុកលើវិស័យសាងសង់បាននិងកំពុងដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងវិស័យសំណង់។ បន្ទាប់ពីច្បាប់សំណង់ត្រូវបានអនុម័តឡើងនៅឆ្នាំ ២០១៩ រាល់សំណង់ទាំងអស់ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ និងមានភាពតឹងរឹងចាប់តាំងពីដំណាក់កាលចេញគម្រោងប្លង់ រហូតដល់ការបិទការដ្ឋានសាងសង់។[72] ជាដំបូង រាល់សំណង់ទាំងអស់ត្រូវមានគម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងបង្គុំម្ចាស់ ដែលមានបញ្ជាក់គុណភាពពីក្រុមហ៊ុនដែលត្រូវ

---

[66] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ១៥ តុលា ២០២១; អនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់វិនិយោគ, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥។

[67] ដដែល។

[68] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១៩/០១៧, ០២ វិច្ឆិកា ២០១៩។

[69] ប្រកាសរបស់ក្រសួងពាណិជ្ជកម្មស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ ២៩០ ព.ណ ចបពប្រក, ៩ តុលា ២០២០, ប្រការ ៣។

[70] ច្បាប់ស្តីពីការប្រកួតប្រជែង, លេខ នស/រកម/១០២១/០១៣, ០៥ តុលា ២០២១។

[71] ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់, លេខ នស/រកម/១១១៩/០១៦, ០២ វិច្ឆិកា ២០១៩។

[72] ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩; អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យនិងការបញ្ជាក់សំណង់, លេខ ២២៥ អនក្រ.បក, ៣០ ធ្នូ ២០២០; អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ ២២៤ អនក្រ.បក, ៣០ ធ្នូ ២០២០; អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់, លេខ ២២៦ អនក្រ.បក, ៣០ ធ្នូ ២០២០។

បានទទួលស្គាល់ដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។[73] បន្ទាប់មក ម្ចាស់សំណង់ ត្រូវស្នើសុំលិខិតបើកការដ្ឋានសាង់សង់ពីស្ថាប័នមានសមត្ថកិច្ច ដែលតម្រូវឱ្យសង់ត្រឹមតែគ្រឹះនៃសំណង់តែប៉ុណ្ណោះ ទើបម្ចាស់សំណង់ ត្រូវបានអនុញ្ញាតស្នើសុំលិខិតអនុញ្ញាតសាងសង់។[74] អំឡុងពេលសាងសង់ ម្ចាស់សំណង់ ត្រូវស្នើសុំក្រុមហ៊ុនដែលទទួលស្គាល់ពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីត្រួតពិនិត្យសំណង់ និងគ្រឿងបង្គុំឱ្យស្របតាមគម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងបង្គុំ។ នៅពេលដែលសំណង់បានសាងសង់រួមរាល់ជាស្ថាពរ ម្ចាស់សំណង់ត្រូវស្នើសុំលិខិតបិទការដ្ឋានសាងសង់ពីស្ថាប័នមានសមត្ថកិច្ច និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។[75] ការតម្រូវឱ្យមានលិខិតអនុញ្ញាតពីមួយដំណាក់កាលទៅមួយដំណាក់កាល គឺជាធានានូវគុណភាពសំណង់ និងសុវត្ថភាពអ្នកប្រើប្រាស់សំណង់។ ក្រៅពីវិស័យសំណង់ ការប្រើប្រាស់បច្ចេកវិទ្យានៅប្រទេសកម្ពុជាក៏មានការកើនឡើងជាលំដាប់ផងដែរ។ ហេតុដូច្នេះ ច្បាប់ស្តីពីទូរគមនាគន៍ ត្រូវបានអនុម័តឡើងដើម្បីគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្មទូរគមនាគមន៍នៅកម្ពុជា ដូចជា ការផ្គត់ផ្គង់ និងប្រើប្រាស់សេវាទូរស័ព្ទចល័ត ប្រព័ន្ធអ៊ីនធឺណែត និងការគ្រប់គ្រងសុវត្ថិភាពនៃទិន្នន័យឯកជនរបស់បុគ្គល។[76] សមិទ្ធផលទាំងនេះឆ្លុះបញ្ចាំងពីឆន្ទៈ និងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងអនុម័តច្បាប់សំខាន់ៗសម្រាប់បម្រើដល់ការវិនិយោគនៅកម្ពុជា។

[73] ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ស្តីពីបែបបទនៃការងារត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងបង្គុំសំណង់, លេខ ១០៩ ដនស/ប្រ.ក/នី.ក, ២២ វិច្ឆិកា ២០២១, ប្រការ១២។

[74] ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ ០១៣ ដនសប្រក./នី.ក, ២០ មករា ២០២២, ប្រការ ៧។

[75] ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់សំណង់, លេខ ១៧៧ ដនស/ប្រក., ០៦ ធ្នូ ២០១៩, ប្រការ១៣។

[76] ច្បាប់ស្តីពីទូរគមនាគមន៍, លេខ នស/រកម/១២១៥/០១៧, ១៧ ធ្នូ ២០១៥; អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអីនធឺណិតជាតិ, លេខ ២៣ អនក្រ.បក, ១៦ កុម្ភៈ ២០២១។

# ជំពូកទី២
# របបគតិយុត្តនៃគម្រោងវិនិយោគមាន
# លក្ខណសម្បត្តិគ្រប់គ្រាន់

# ជំពូកទី២ របបគតិយុត្តនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

## ២.១. សញ្ញាណទូទៅនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

### ២.១.១. និយមន័យ និងប្រភេទនៃគម្រោងវិនិយោគ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលហៅកាត់ថា គ.ល.គ. គឺជាគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ហើយមានសិទ្ធិក្នុងការទទួលបានការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធនានា។[77]

ប្រភេទនៃ គ.ល.គ. ពុំមានការប្រែប្រួលអ្វីឡើយរវាងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគឆ្នាំ និងច្បាប់ស្តីពីវិនិយោគកម្ពុជាថ្មី ដែលត្រូវបានបែងចែកជា ៣ ប្រភេទដដែលពោលគឺៈ (១) គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ (២) គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ និង (៣) គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក ដែលពុំមានការប្រែប្រួលអ្វីឡើយរវាងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគឆ្នាំ និងច្បាប់ស្តីពីវិនិយោគកម្ពុជាថ្មី។[78] គ.ល.គ. បម្រើឱ្យការនាំចេញ សំដៅដល់ គ.ល.គ. ដែលលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។[79] ចំណែក គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រ គឺជាប្រភេទ គ.ល.គ. ដែលផ្គត់ផ្គង់ផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយដល់ឧស្សាហកម្មនាំចេញ។[80] សម្រាប់ គ.ល.គ. បម្រើទីផ្សារក្នុងស្រុកវិញគឺ សំដៅដល់ គ.ល.គ. ដែលមិនបម្រើឱ្យការនាំចេញ។[81]

### ២.១.២. អង្គភាពទទួលបន្ទុកការវិនិយោគ

យោងតាមច្បាប់ស្តីពីវិនិយោគកម្ពុជា អង្គភាពដែលទទួលបន្ទុកការវិនិយោគរួមមាន (**២.១.២.១.**) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង (**២.១.២.២.**) អនុគណៈកម្មាធិការរាជធានីខេត្ត។

#### ២.១.២.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា ក.អ.ក. ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៤ ក្នុងនាមជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ដែលបំពេញមុខងារជាសេនាធិការ និងជាច្រកចេញចូលតែមួយរបស់

[77] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា៣។
[78] ដដែល; ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា២ ថ្មី។
[79] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា៣។
[80] ដដែល។
[81] ដដែល។

រាជរដ្ឋាភិបាល។[82] ស្ថាប័ននេះមានមុខងារក្នុងការត្រួតពិនិត្យព្រមទាំងសម្រេចលើ ការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការវិនិយោគលើវិស័យឯកជន និងសាធារណៈ និងការបង្កើតក៏ដូចជាគ្រប់គ្រងលើតំបន់សេដ្ឋកិច្ចពិសេស។[83] ក្នុងភារកិច្ចនេះ ក.អ.ក. មានតួនាទីធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីសម្របសម្រួលការចាត់ចែង និងប្រើប្រាស់ហិរញ្ញប្បទានដែលទទួលបាន។[84] លើសពីនេះ ក.អ.ក. ក៏មានតួនាទីជាអ្នកសម្របសម្រួលការងាររវាងក្រសួង និងស្ថាប័នរដ្ឋនានា និងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកវិនិយោគ ដើម្បីផ្តល់លក្ខណៈងាយស្រួល និងសម្រួលដល់ដំណើរការការងាររបស់ពួកគេ។[85] ថ្វីត្បិតតែ ក.អ.ក. មានសមត្ថកិច្ចគ្រប់គ្រងនិងត្រួតពិនិត្យលើគម្រោងវិនិយោគក្តី ក.អ.ក. ត្រូវសុំយោបល់ពីគណៈរដ្ឋមន្ត្រីទៅលើគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិដូចតទៅ៖ (១) ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិកឡើងទៅ (២) មានវេទយិតភាពខាងនយោបាយ (៣) ពាក់ព័ន្ធនឹងការរុករក និងធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ (៤) អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន (៥) គម្រោងយុទ្ធសាស្ត្ររយៈពេលវែង និង (៦) គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។[86]

រចនាសម្ព័ន្ធរបស់ ក.អ.ក. រួមមាន (១) គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា គ.ជ.នា. (២) គណៈកម្មាធិការវិនិយោគកម្ពុជា ដែលហៅកាត់ថា គ.វ.ក. (៣) គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដែលហៅកាត់ថា គ.ស.ព. និង (៤) អគ្គលេខាធិការដ្ឋាន។[87] នៅក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ គ.ជ.នា. ទទួលបន្ទុកលើទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយដល់កម្ពុជាដែលរួមមាន ប្រទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការទទួលជំនួយ និង/ឬការគ្រប់គ្រងហិរញ្ញប្បទានប្រតិបត្តិការទាំងនេះ។[88] លើសពីនេះ គ.ជ.នា ក៏ចូលរួមក្នុងការគ្រប់គ្រងលើកិច្ចការវិនិយោគសាធារណៈ ដោយធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងន័យបែងចែកការប្រើប្រាស់ធនធានទាំងក្នុងនិងក្រៅប្រទេសដើម្បីបម្រើដល់ការអភិវឌ្ឍជាតិ។[89] គ.វ.ក. ទទួលខុសត្រូវគ្រប់គ្រងលើការវិនិយោគឯកជន ជាពិសេសទាក់ទិននឹងការផ្សព្វផ្សាយគម្រោង ការផ្តួចផ្តើម ការផ្តល់យោបល់

[82] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ ៦០ អនក្រ.បក, ០៥ មេសា ២០១៦, មាត្រា១០។
[83] ដដែល។
[84] ដដែល។
[85] ដដែល។
[86] ដដែល, មាត្រា១១។
[87] ដដែល, មាត្រា២។
[88] ដដែល, មាត្រា១៣។
[89] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ ៦០ អនក្រ.បក, ០៥ មេសា ២០១៦, មាត្រា១៣។

និងស្នើជូនរាជរដ្ឋាភិបាលជុំវិញការរៀបចំនិងការកែលម្អច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីជាការលើកទឹកចិត្តដល់អ្នកវិនិយោគ តាមរយៈការផ្តល់លក្ខខណ្ឌអនុគ្រោះ និងអត្ថប្រយោជន៍ផ្សេងៗ។[90] គ.ស.ព. មានតួនាទីត្រួតពិនិត្យ គ្រប់គ្រង និងសម្រេចលើសំណើរសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាទាំងការបង្កើតឡើងដោយរដ្ឋ ឯកជនចម្រុះរដ្ឋ ឬឯកជនក្តី។[91] ក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស គ.ស.ព. ត្រូវធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ និងសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់ទីតាំងភូមិសាស្ត្រសំខាន់ៗ និងទាក់ទាញការវិនិយោគតាមរយៈការផ្សព្វផ្សាយអំពីសក្តានុពលនៃតំបន់ទាំងនេះ។[92]អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការនីមួយៗ មានតួនាទីគ្រប់គ្រងការងារ រៀបចំរបៀបវារៈ កិច្ចប្រជុំ និងឯកសារនានាជូនគណៈកម្មាធិការរបស់ខ្លួន។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាននីមួយៗត្រូវតាមដានការអនុវត្តកម្មវិធី និងគម្រោងវិនិយោគដោយធ្វើការសហការនឹងបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុបសម្រាប់ដាក់ជូនគណៈកម្មាធិការត្រួតពិនិត្យ និងកែតម្រូវតាមការចាំបាច់។[93]

### ២.១.២.២. អនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត

អនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត ដែលហៅកាត់ថា អ.គ.វ. ត្រូវបានបង្កើតឡើងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនវិនិយោគិន ការពិនិត្យ សម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[94] អ.គ.វ. មានសមត្ថកិច្ចចុះបញ្ជីនូវសំណើគ.ល.គ. ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ បន្ទាប់ពីបានចុះបញ្ជី អ.គ.វ. នឹងផ្តល់ឯកសារពាក់ព័ន្ធនឹងគ.ល.គ. ទៅក.អ.ក. ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យ និងផ្តល់ការលើកទឹកចិត្តលើសំណើរបស់អ្នកវិនិយោគ។[95] អ.គ.វ. ដើរតួជាយន្តការច្រកចេញចូលតែមួយលើការងារវិនិយោគនៅរាជធានី ខេត្តដូចគ្នាទៅនឹងក.អ.ក. ដែលនីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងការផ្តល់ការលើកទឹកចិត្ត គឺអនុវត្តទៅតាមនីតិវិធីរបស់ក.អ.ក ដូចដែលមានចែងជាធរមាននៅក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគ។[96]

---

[90] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ ៦០ អនក្រ.បក, ០៥ មេសា ២០១៦, មាត្រា១៧។

[91] ដដែល, មាត្រា២១។

[92] ដដែល។

[93] ដដែល, មាត្រា២៦-២៩។

[94] ដដែល, មាត្រា៣។

[95] ដដែល។

[96] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត, លេខ ១២០ អនក្រ.បក, ២០ មិថុនា ២០២២, មាត្រា៦។

### ២.១.៣. ការលើកទឹកចិត្តចំពោះការវិនិយោគ

រាជរដ្ឋាភិបាលនឹងផ្តល់ការលើកទឹកចិត្តចំពោះវិស័យ និងសកម្មភាពវិនិយោគមួយចំនួនដែលត្រូវបានចាត់ទុកថាជា វិស័យដែលមានសក្តានុពលសម្រាប់ជំរុញដល់ការរីកចម្រើនសេដ្ឋកិច្ចរបស់កម្ពុជា។ ក្នុងនោះមាន វិស័យដូចជា ឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ ឧស្សាហកម្មកម្មន្តសាលមានជាអាទិ៍ គ្រឿងអគ្គិសនី អេឡិចត្រូនិក គ្រឿងបន្លាស់ និងគ្រឿងម៉ាស៊ីន ឧស្សាហកម្មដែលបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលលោក កសិឧស្សាហកម្ម និងការកែច្នៃចំណីអាហារ ឧស្សាហកម្មឌីជីថល ព្រមទាំងឧស្សាហកម្មគាំទ្រដល់វិស័យទេសចរណ៍ កសិកម្ម កម្មន្តសាល និងឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលលោក។[97] លើសពីនេះ រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តផងដែរចំពោះការវិនិយោគលើវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ឡូជីស្ទិក ថាមពលបៃតង ការវិនិយោគលើសហគ្រាសធុនតូច និងមធ្យម និងការវិនិយោគលើការការពារបរិស្ថាន។[98] ក្រៅពីវិស័យដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលអាចផ្តល់ការលើកទឹកចិត្តចំពោះវិស័យ និង/ឬ សកម្មភាពវិនិយោគដទៃទៀត ប្រសិនបើយល់ឃើញថាវាមានសក្តានុពលដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។[99]

ចំពោះគម្រោងវិនិយោគនៅក្នុងវិស័យខាងលើដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាគ.ល.គ. នឹងទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬពន្ធគយទាំងស្រុង ឬមួយផ្នែក វៀរលែងតែគម្រោងវិនិយោគទាំងនេះស្ថិតក្នុងវិស័យដែលមានក្នុងបញ្ជីអវិជ្ជមាន។[100] គ.ល.គ. មានសិទ្ធិទទួលបាន (**២.១.៣.១.**) ការលើកទឹកចិត្តជាមូលដ្ឋាន និង (**២.១.៣.២.**) ការលើកទឹកចិត្តបន្ថែម។

#### ២.១.៣.១. ការលើកទឹកចិត្តជាមូលដ្ឋាន

ចំណុចដែលគួរឱ្យកត់សម្គាល់នៅក្នុងផ្នែកនេះគឺ អត្ថប្រយោជន៍បន្ថែមដែលម្ចាស់ គ.ល.គ. នឹងទទួលបានក្រោមច្បាប់ស្តីពីវិនិយោគថ្មី ដែលមានលក្ខណៈខុសគ្នាច្រើនពីការលើកទឹកចិត្តក្នុងច្បាប់ស្តីពីវិនិយោគចាស់ ដោយហេតុថាច្បាប់ចាស់ផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូលតែ ៣ ឆ្នាំ ដំបូងប៉ុណ្ណោះ បន្ទាប់ពីផុតរយៈពេលនេះ ម្ចាស់ គ.ល.គ. នឹងត្រូវបង់ពន្ធពេញលេញជូនរដ្ឋ។ ដោយឡែកនៅក្នុងច្បាប់ស្តីពីវិនិយោគថ្មី ម្ចាស់គ.ល.គ. មានសិទ្ធិជ្រើសរើសផែនការលើទឹកចិត្តណាមួយ ក្នុងចំណោមជម្រើសទាំងពីរខាងក្រោម។

---

[97] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២៤។

[98] ដដែល។

[99] ដដែល។

[100] ដដែល, មាត្រា២៥។

ក្នុងជម្រើសទី១ ម្ចាស់គម្រោងនឹងទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេល ៣ ឆ្នាំ ដល់ ៩ ឆ្នាំ ទៅអាស្រ័យទៅតាមវិស័យ និងសកម្មភាពវិនិយោគដោយគិតចាប់ពីពេលទទួលបានប្រាក់ចំណូលលើកដំបូង។ [101] ក្រោយពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ម្ចាស់គម្រោងនឹងទទួលបានការលើកទឹកចិត្តចំពោះការបង់ពន្ធលើប្រាក់ចំណូល គណនាទៅតាមអត្រាកំណើនតាមពេលធៀបនឹងទឹកប្រាក់ពន្ធត្រូវបង់សរុបដូចជា ២៥% សម្រាប់ ២ ឆ្នាំ ដំបូង បន្ទាប់មក ៥០% សម្រាប់ ២ ឆ្នាំបន្ទាប់ និង ៧៥% សម្រាប់ ២ ឆ្នាំចុងក្រោយ។ [102] លើសពីនេះ ម្ចាស់គម្រោងមានសិទ្ធិទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងអំឡុងពេលនៃការលើកលែងពន្ធលើប្រាក់ចំណូល ការលើកលែងពន្ធអប្បបរមាដោយតម្រូវឱ្យមានរបាយការណ៍សវនកម្មឯករាជ្យ និងការលើកលែងពន្ធអាករនាំចេញលើកលែងតែមានការចែងដោយឡែកក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត។[103]

ក្នុងជម្រើសទី២ ម្ចាស់គម្រោងទទួលបានសិទ្ធិកាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេសផ្អែកតាមបទបញ្ញត្តិចែងជាធរមាន និងសិទ្ធិកាត់កង ២០០% លើចំណាយជាក់លាក់ផ្សេងទៀតសម្រាប់រយៈពេលរហូតដល់ ៩ ឆ្នាំ។ លើសពីនេះ ម្ចាស់គម្រោងមានសិទ្ធិទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ទៅតាមវិស័យ និងសកម្មភាពវិនិយោគ ការលើកលែងពន្ធអប្បបរមាដោយតម្រូវឱ្យមានរបាយការណ៍សវនកម្មឯករាជ្យ និងការលើកលែងអាករនាំចេញ លើកលែងតែមានការចែងដោយឡែកក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

អំពីការលើកលែងពន្ធគយ និងអាករពិសេស ច្បាប់ស្តីពីវិនិយោគចាស់ និងច្បាប់ថ្មី ផ្តល់ការលើកទឹកចិត្តដូចគ្នាដល់ គ.ល.គ. បម្រើឱ្យការនាំចេញ និង គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.គ. បម្រើឱ្យការនាំចេញ។ ក្នុងនោះមានសិទ្ធិនាំចូល និងការលើកលែងចំពោះពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមសម្រាប់សម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។[104] ចំណែកគ.ល.គ. បម្រើទីផ្សារក្នុងស្រុកវិញ រដ្ឋរ៉ាប់រងជំនួសដូចគ្នាទៅលើពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមចំពោះ

[101] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២៦។

[102] ដដែល។

[103] ដដែល។

[104] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២៦។

សម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខាផលិតកម្ម។[105] យ៉ាងណាមិញ ការអនុគ្រោះពន្ធលើធាតុចូលផលិតកម្មនឹងត្រូវកំណត់ដោយច្បាប់ និង/ឬ អនុក្រឹត្យដោយឡែក។[106]

### ២.១.៣.២. ការលើកទឹកចិត្តបន្ថែម

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋាន ម្ចាស់ គ.ល.គ. មានសិទ្ធិទទួលបានការលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញវត្ថុធាតុដើមដែលត្រូវបានផលិតក្នុងស្រុកសម្រាប់បម្រើដល់សកម្មភាព គ.ល.គ. និងការកាត់កងចំណាយក្នុងអត្រា ១៥០% ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាព (១) ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ (២) ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ (៣) ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀតសម្រាប់កម្មករនិយោជិត (៤) ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើឱ្យខ្សែប្រវាក់ផលិតកម្ម (៥) ការផ្តល់ការលើកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនចំពោះការធ្វើដំណើររវាងរោងចក្រ និងកន្លែងស្នាក់នៅ ការផ្តល់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានជាអាទិ៍ និង (៦) ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះការពង្រីកនៃ គ.ល.គ. ត្រូវកំណត់ដោយអនុក្រឹត្យ។ [107]

### ២.១.៤. ការធានាលើការវិនិយោគ

ការធានាលើការវិនិយោគដោយរាជរដ្ឋាភិបាលនៃប្រទេសសាមីពិតជាមានសារៈសំខាន់ ដោយការធានានេះគឺជាការផ្តល់ទំនុកចិត្តមួយដល់វិនិយោគិនក្នុងការចូលមកដាក់ទុន និងធ្វើពាណិជ្ជកម្មក្នុងប្រទេសមួយ។ ដោយសង្កេតឃើញពីចំណុចនេះ រាជរដ្ឋាភិបាលកម្ពុជាធានាក្នុងការផ្តល់សំណងសមរម្យ ក្នុងករណីគម្រោងវិនិយោគទទួលរងនូវការខូចខាត ដោយសារជម្លោះប្រដាប់អាវុធ ឬសង្គ្រាមស៊ីវិល ឬការដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន។[108] លើសពីនេះរាជរដ្ឋាភិបាលនឹងមិនធ្វើអស្សាមិករណ៍ ឬជាតូបនីយកម្ម ទោះដោយផ្ទាល់ ឬប្រយោលក្តីដែលនាំឱ្យប៉ះពាល់ដល់ គ.ល.គ.។ [109] ប្រសិនបើស្ថិតក្នុងករណីចាំបាច់ដែលតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវធ្វើអស្សាមិករណ៍ដើម្បីជាប្រយោជន៍សាធារណៈ នោះអាស្សាមិករណ៍ត្រូវធ្វើឡើងប្រកបដោយយុត្តិធម៌ មិនមានការរើសអើង និងផ្តល់សំណង់ត្រឹមត្រូវ សមរម្យដោយអនុលោមទៅតាមច្បាប់ជាធរមាន។[110] ទាក់ទងទៅនឹងបញ្ហា

[105] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២៦។

[106] ដដែល។

[107] ដដែល, មាត្រា២៧។

[108] ដដែល, មាត្រា១៥។

[109] ដដែល, មាត្រា១៧។

[110] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា១៧។

ដីធ្លីវិញ កម្មសិទ្ធិលើដីធ្លីត្រូវបានអនុញ្ញាតចំពោះតែវិនិយោគិនដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ [111] នេះគឺអនុលោមទៅតាមច្បាប់ភូមិបាលដែលហាមឃាត់ជនបរទេសចំពោះការកាន់កាប់កម្មសិទ្ធិលើដី។[112]

វិនិយោគិននៃ គ.ល.គ. ទទួលបានការការពារលើកម្មសិទ្ធិបញ្ញាដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា[113] ដែលបច្ចុប្បន្នកម្ពុជាមានការទទួលស្គាល់ និងផ្តល់ការការពារទៅលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល[114] ពាណិជ្ជនាមនិងម៉ាក[115] ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម [116] និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ [117] ដោយហេតុថាប្រទេសកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី [118] ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាពុំជ្រៀតជ្រែកលើការកំណត់តម្លៃទីផ្សារនៃផលិតផលទំនិញ ឬសេវានានាដែលបង្កើតដោយគម្រោងវិនិយោគឡើយ។[119] ដោយឡែកអាចមាននូវករណីលើកលែងមួយចំនួនពាក់ព័ន្ធនឹងសកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ ដែលមន្ត្រីមានសមត្ថកិច្ចអាចចាត់វិធានការ ឬធ្វើការអន្តរាគមន៍ដោយយោងទៅតាមច្បាប់ស្តីពីការប្រកួតប្រជែង។ [120] ក្រៅពីនេះក៏មានមុខទំនិញមួយចំនួនដែលរាជរដ្ឋាភិបាលបានចូលរួមសម្របសម្រួលដើម្បីប្រញ្រោបជាព័ត៌មានដល់សាធារណជនអំពីតម្លៃនៃទំនិញរួមមាន តម្លៃប្រេងសាំង[121] និងតម្លៃអគ្គិសនី[122] ជាអាទិ៍។

### ២.១.៥. សកម្មភាពវិនិយោគ និងវិស័យហាមឃាត់

ទន្ទឹមនឹងការលើកទឹកចិត្តវិនិយោគចំពោះសកម្មភាពវិនិយោគ និងវិស័យ ដូចដែលបានលើកឡើងពីខាងលើរាជរដ្ឋាភិបាលមានការហាមឃាត់ចំពោះសកម្មភាពវិនិយោគ និងវិស័យមួយចំនួនដូចជា៖ (១) ផលិតកម្ម

[111] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២១។

[112] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៨។

[113] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា២០។

[114] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា។

[115] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២។

[116] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, នស/រកម/០១០៣/០០៥, ២២ មករា ២០០៣។

[117] ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, លេខ នស/រកម/០១១៤/០០៦, ២២ មករា ២០១៤។

[118] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា៥៦។

[119] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ២៩ កញ្ញា ២០២១, មាត្រា១៨។

[120] ច្បាប់ស្តីពីការប្រកួតប្រជែង, នស/រកម/១០២១/០១៣, ០៥ តុលា ២០២១។

[121] ប្រកាសអន្តរក្រសួងរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពលស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា, លេខ ០៩៨ ពណ.អរង.ប្រក, ០៩ មីនា ២០១៦។

[122] សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីការពិគ្រោះយោបល់សាធារណៈ លើគម្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីពីប្រភពបណ្តាញជាតិ សម្រាប់លក់ឱ្យអ្នកកាន់អាជ្ញាបណ្ណដែលទិញអគ្គិសនីពីអគ្គិសនីកម្ពុជា និងពីអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនសម្រាប់ឆ្នាំ២០២២, លេខ ១៣២.សណ.២១ អអក, ១០ កញ្ញា ២០២១។

កែច្នៃសារធាតុប្រព័ន្ធសរសៃប្រសាទ និងសារធាតុញៀន (២) ផលិតកម្មគ្រឿងគីមីពុល ថ្នាំពុលកសិកម្ម និង ទំនិញដទៃទៀតតាមរយៈការប្រើប្រាស់សារធាតុគីមីដែលឃាត់ដោយបញ្ញត្តិជាតិ និងអន្តរជាតិដែលនាំផល ប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន (៣) ការកែច្នៃ ការផលិតអគ្គិសនី ដោយប្រើប្រាស់កាកសំណល់ គ្រប់ប្រភេទដែលនាំចូលពីបរទេស និង (៤) ការធ្វើអាជីវកម្មព្រៃឈើដែលត្រូវបានហាមឃាត់អនុលោមតាម ច្បាប់ស្តីពីព្រៃឈើ។[123]

## ២.២. នីតិវិធីចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានលើកទឹកចិត្ត និង ផ្តល់នូវផលប្រយោជន៍ជាច្រើនដល់ អ្នកវិនិយោគ។ ដូច្នេះ បុគ្គលណាដែលមានបំណងចង់អនុវត្ត គ.ល.គ. (**២.២.១.**) ត្រូវដឹងអំពីដែនសមត្ថកិច្ចក្នុង ការចុះបញ្ជី និងដាក់សំណើទៅ ក.អ.ក. តាមរយៈ (**២.២.២.**) នីតិវិធីនៃការចុះបញ្ជី គ.ល.គ. និង (**២.២.៣**) កាតព្វកិច្ចរាយការណ៍ស្តីពីពន្ធដារ និងពន្ធគយ។ លើសពីនេះ (**២.២.៤.**) ម្ចាស់គម្រោងវិនិយោគមានកាតព្វកិច្ច ស្នើសុំការយល់ព្រមផ្សេងៗពី ក.អ.ក. ហើយអ្នកវិនិយោគគួរយល់ដឹងផលដែរពីការប្រឈមនឹង (**២.២.៣.**) ការ ដកហូត គ.ល.គ. ប្រសិនបើមានការអនុវត្តមិនបានល្អ។

### ២.២.១. យុត្តាធិការនៃការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

មុនពេលដាក់ពាក្យស្នើសុំចុះបញ្ជីគ.ល.គ. អ្នកវិនិយោគត្រូវដឹងអំពីសមត្ថកិច្ចនៃការចុះបញ្ជី ដោយហេតុ ថាគ.ល.គ. ខ្លះតម្រូវឱ្យចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯខ្លះទៀតត្រូវចុះនៅអនុគណៈកម្មាធិការវិនិយោគ រាជធានីខេត្ត។ គ.ល.គ. ដែលតម្រូវចុះបញ្ជីនៅក.អ.ក. លុះត្រាតែគម្រោងវិនិយោគ (១) មានទំហំដើមទុនលើស ពី ៥,០០០,០០០ ដុល្លារអាមេរិក (២) មានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងលើសពី ២ (ពីរ) រាជធានីខេត្ត ឡើងទៅ និង (៣) ស្ថិតនៅក្នុងតំបន់សមត្ថកិច្ចពិសេស[124] ៤) ស្ថិតក្រោមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និង ឯកជន ៥) ពាក់ព័ន្ធនឹងការរុករក និងធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ ៦) ពាក់ព័ន្ធនឹងវិស័យថាមពល ៧)

[123] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ផ្នែកទី១ នៃឧបសម្ព័ន្ធទី១។

[124] អនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស, លេខ ១៤៨ អនក្រ.បក, ២៩ ធ្នូ ២០០៥, មាត្រា២ បានកំណត់ថា "តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចមានតំបន់ឧស្សាកម្មទូទៅ ឬ/និងតំបន់ផលិតកែច្នៃនាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណាញឧលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។"

ស្ថិតក្នុងបញ្ជីអវិជ្ជមាន ៨) មានការប៉ះពាល់ខ្លាំងដល់សន្តិសុខជាតិ ធនធានធម្មជាតិ ការការពារជីវចម្រុះ។[125] ប្រសិនបើគម្រោងវិនិយោគមិនស្ថិតក្នុងចំណុចទាំង ៨ ដូចមានរៀបរាប់ខាងលើទេ ត្រូវទៅចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត។[126]

### ២.២.២. នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

នីតិវិធីក្នុងការចុះបញ្ជី គ.ល.គ. ត្រូវបានកំណត់ដូចតទៅ៖ (**២.២.១.១.**) ការដាក់ពាក្យស្នើសុំ (**២.២.១.២**) ការអនុញ្ញាត ឬបដិសេធការចុះបញ្ជី និង (**២.២.១.៣**) ការចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ និង ការចាប់ផ្តើមគម្រោងវិនិយោគ។

#### ២.២.១.១. ការដាក់ពាក្យស្នើសុំ

អ្នកស្នើសុំត្រូវដាក់ពាក្យសុំដោយបញ្ជាក់ឱ្យបានច្បាស់អំពី សកម្មភាពវិនិយោគតាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ត្រូវមានការចុះហត្ថលេខាឱ្យបានត្រឹមត្រូវពីម្ចាស់គម្រោងវិនិយោគ ឬអ្នកតំណាងដែលមានការប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ប្រាក់រដ្ឋបាលចំនួន ៧,000,000 រៀលសម្រាប់ថ្លៃសេវារដ្ឋបាល។[127] នៅក្នុងទម្រង់បែបបទនៃសំណើរសុំវិនិយោគ វិនិយោគិនត្រូវបំពេញនូវព័ត៌មានសំខាន់ៗបីគឺ (១) រចនាសម្ព័ន្ធក្រុមហ៊ុន (២) ពាក្យស្នើសុំវិនិយោគ និង (៣) ការធានាអះអាងក្នុងនាមជាម្ចាស់គម្រោង[128] ដែលនឹងមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

ចំពោះព័ត៌មានរចនាសម្ព័ន្ធក្រុមហ៊ុន វិនិយោគិនត្រូវបង្ហាញអំពីព័ត៌មានទូទៅរបស់ក្រុមហ៊ុនដែលរួមមានឈ្មោះ អាសយដ្ឋាន ប្រភេទក្រុមហ៊ុន (ក្រុមសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនពាណិជ្ជកម្មបរទេស) ដើមទុនចុះបញ្ជី និងលិខិតបញ្ជាក់ពីការតម្កល់ប្រាក់នៅធនាគារ។[129] លើសពីនេះក៏ត្រូវបញ្ជាក់អំពីសមាសភាពរបស់ក្រុមហ៊ុន ជាពិសេសទាក់ទងទៅនឹងព័ត៌មានរបស់ម្ចាស់ភាគហ៊ុន និងសមាសភាពក្រុមប្រឹក្សាភិបាល។[130]

---

[125] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត, លេខ ១២០ អនក្រ.បក, ២០ មិថុនា ២០២២, មាត្រា១០។

[126] ដដែល។

[127] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៥។

[128] ដដែល, ឧបសម្ព័ន្ធទី ៣។

[129] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី ៣។

[130] ដដែល។

សម្រាប់ពាក្យស្នើសុំវិនិយោគវិញ វិនិយោគិនត្រូវផ្តល់ជូននូវព័ត៌មានទូទៅនៃសកម្មភាពវិនិយោគរបស់ខ្លួន និងជម្រើសនៃការលើកលែងបន្ទាប់ពីទទួលបានការចុះបញ្ជី គ.ល.គ.។[131] ព័ត៌មានទូទៅតម្រូវឱ្យមានការបង្ហាញអំពីសកម្មភាពវិនិយោគ វិស័យវិនិយោគ ព័ត៌មានអ្នកដាក់ពាក្យសុំ ទុនវិនិយោគសរុប ប្រភពទុនវិនិយោគ ទីតាំងវិនិយោគ ទំហំដីធ្លី កម្មវិធីវិនិយោគ (រយៈពេលចាប់ផ្តើមសកម្មភាព និងការព្យាករណ៍លើការបញ្ចប់សកម្មភាព) ព័ត៌មានស្តីពីផលិតផល តម្រូវការពលកម្ម តម្រូវការវត្ថុធាតុដើម និង តម្រូវការថាមពល និងទឹក។[132] ឯជម្រើសនៃការលើកលែងវិញគឺ ជម្រើសណាមួយក្នុងចំណោមពីរដែលបានរៀបរាប់ក្នុងចំណុច ២.១.៣. ខាងលើ។ ក្រៅពីនេះវិនិយោគិនត្រូវផ្តល់ព័ត៌មានស្តីពីបរិស្ថានដូចជា រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចចេញចូល ទីតាំងវិនិយោគ ដំណើរការបញ្ចេញទឹកស្អុយ ទីតាំងសម្រាប់ប្រើប្រាស់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ ការបញ្ចេញឧស្ម័ន ប្រភពដែលមានសម្លេង និងភាពរំញ័រកើនឡើង ព្រមទាំងស្ថានភាពស្នាក់នៅរបស់បុគ្គលិក ឬកម្មករ។[133] លើសពីនេះអ្នកវិនិយោគត្រូវផ្តល់ព័ត៌មានផ្នែកពន្ធដារ ទាក់ទងនឹងកាតព្វកិច្ចប្រកាសពន្ធនានាដែលមានជាអាទិ៍ ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវា និងអាករដែលត្រូវបង់នៅពេលនាំចូល និងពន្ធអាករដទៃទៀត។ ដូច្នេះ វិនិយោគិន មានកាតព្វកិច្ចក្នុងការចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាព នៅរដ្ឋបាលសារពើពន្ធ។[134] ជាចុងក្រោយ វិនិយោគិនត្រូវភ្ជាក់មកជាមួយនូវ លក្ខន្តិកៈក្រុមហ៊ុន រូបថត លិខិតថតចម្លង លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណរបស់ម្ចាស់ភាគហ៊ុននីមួយៗ។[135]

បន្ថែមពីលើព័ត៌មានចាំបាច់ដែលបង្ហាញខាងលើ វិនិយោគិនត្រូវធ្វើការអះអាង និងការធានាក្នុងនាមជាម្ចាស់គម្រោងថាគម្រោងរបស់ខ្លួនមិនស្ថិតក្នុងបញ្ជីអវិជ្ជមាន ហើយរាល់ព័ត៌មានដែលបានសរសេរក្នុងពាក្យស្នើសុំពិតជាត្រឹមត្រូវ និងមិនមានការក្លែងបន្លំឡើយ។[136] ប្រសិនបើបុគ្គលណាមួយមានបំណងធ្វើការវិនិយោគ

[131] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី៣។

[132] ដដែល។

[133] ដដែល។

[134] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុបន្នភាពព័ត៌មានអ្នកជាប់ពន្ធ, លេខ ៧០១ សហវ.ប្រក, ១៤ សីហា ២០២០, មាត្រា៤ និង៥។

[135] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី៣។

[136] ដដែល។

និងដំណើការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ បុគ្គលនោះត្រូវដាក់សំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពនីមួយៗ ដើម្បីដំណើរការគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នីមួយៗ។[137]

### ២.២.១.២. ការអនុញ្ញាត ឬការបដិសេធការចុះបញ្ជី

រាល់ការស្នើសុំ គ.ល.គ. មិនមែនសុទ្ធតែទទួលបានការយល់ព្រមទាំងអស់ពី ក.អ.ក. នោះទេ។ ហេតុដូច្នេះហើយ ក.អ.ក. នឹងធ្វើការសម្រេចក្នុងរយៈពេលបន្ទាប់ពីទទួលបានពាក្យស្នើសុំចុះបញ្ជីក្នុងរយៈពេល ៣ (បី) ថ្ងៃអំពីការអនុញ្ញាត ឬ ការបដិសេធ ឬ ការពន្យាពេលចំពោះការចុះបញ្ជី។[138] ក្នុងករណីដែលពាក្យសុំមានលក្ខណៈត្រឹមត្រូវ ដោយបានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីគម្រោងវិនិយោគ សកម្មភាពវិនិយោគមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន ហើយអ្នកវិនិយោគមិនដែលទទួលបាន ឬកំពុងតែអនុវត្ត គ.ល.គ.[139] នោះគម្រោងវិនិយោគនឹងទទួលបានការចុះបញ្ជី ហើយ ក.អ.ក. ត្រូវជូនដំណឹងទៅកាន់អ្នកដាក់ពាក្យស្នើសុំ និងចេញវិញ្ញាបនប័ត្រចុះបញ្ជីក្នុងរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការជូនអ្នកស្នើសុំ។[140] វិញ្ញាបនប័ត្រនេះត្រូវបញ្ជាក់អំពីការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដែលជាតម្រូវការស្របច្បាប់សម្រាប់ដំណើរការរបស់ គ.ល.គ.។ ក្នុងនោះត្រូវបង្ហាញផងដែរ អំពីជម្រើសនៃការលើកទឹកចិត្តរបស់អ្នកដាក់ពាក្យស្នើសុំ ការធានាលើការវិនិយោគដែលទទួល និង ការទទួលស្គាល់នូវលក្ខន្តិកៈរបស់នីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោង។[141]

ផ្ទុយទៅវិញ ការស្នើសុំនឹងត្រូវបានបដិសេធ ប្រសិនបើអ្នកស្នើសុំពុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់នៅក្នុងពាក្យស្នើសុំ ឬ សកម្មភាពវិនិយោគស្ថិតក្នុងបញ្ជីអវិជ្ជមាន ឬ អ្នកវិនិយោគធ្លាប់បានទទួល ឬកំពុងទទួលបានការលើកទឹកចិត្ត។[142] ក្នុងការបដិសេធសំណើរសុំចុះបញ្ជី ក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចេញលិខិតបដិសេធជូនដល់អ្នកស្នើសុំ ដោយមានបញ្ជាក់អំពីមូលហេតុនៃការមិនទទួលសំណើរ។ ក្នុងករណីដែលពាក្យស្នើសុំត្រូវបានបដិសេធដោយសារខ្វះខាតព័ត៌មានគ្រប់គ្រាន់ នោះលិខិតបដិសេធត្រូវបង្ហាញពីព័ត៌មានដែលត្រូវបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកស្នើសុំអាចកែតម្រូវ និងដាក់ពាក្យស្នើសុំជាថ្មីទៅ ក.អ.ក.។[143] ដោយឡែកប្រសិនបើគម្រោងវិនិយោគមានលក្ខណៈពិសេសដូចជា មានការពាក់ព័ន្ធដល់ផលប្រយោជន៍ជាតិ

---

[137]អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៥ កថាខណ្ឌ៤។

[138] ដដែល, មាត្រា៦ កថាខណ្ឌ១។

[139] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី ៣។

[140] ដែល, មាត្រា៦ កថាខណ្ឌ៣។

[141] ដដែល។

[142] ដដែល, មាត្រា៦ កថាខណ្ឌ១ ចំណុច ខ។

[143] ដដែល, មាត្រា៦ កថាខណ្ឌ៦។

និងបរិស្ថាន នោះ ក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត មានសិទ្ធិពន្យារពេលការចុះបញ្ជីដោយផ្តល់ព័ត៌មាន និងបញ្ជាក់អំពីមូលហេតុនៃការពន្យារពេលឱ្យបានត្រឹមត្រូវទៅកាន់អ្នកស្នើសុំក្នុងអំឡុងពេល ៣ ថ្ងៃនៃថ្ងៃធ្វើការ។[144]

### ២.២.១.៣. ការចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ និងការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

នៅពេល ក.អ.ក. ចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌរួចហើយ ក.អ.ក. ត្រូវទទួលខុសត្រូវជំនួសមុខឱ្យអ្នកដាក់ពាក្យសុំនូវរាល់ការស្នើសុំ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗរបស់រាជរដ្ឋាភិបាល។[145]កាលបើអ្នកមានវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌទទួលបាននូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានារួចហើយ ក.អ.ក. ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។[146] ក.អ.ក. នឹងចេញវិញ្ញាបនបត្រស្ថាពរនៅក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ នៅពេលដែលក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬភ្នាក់ងារបានយល់ព្រមលើសំណើសុំការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត។[147] នៅពេលដែលវិញ្ញាបនបត្រស្ថាពរបានចេញដោយ ក.អ.ក. នោះអ្នកវិនិយោគដែលបានដាក់ពាក្យស្នើសុំអាចចាប់ផ្តើម គ.ល.គ. បាន។ [148] ក្រាហ្វិកខាងក្រោម គឺជាការសង្ខេបអំពីនីតិវិធីចុះបញ្ជីគ.ល.គ។




រូបទី៤៖ ការសង្ខេបនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

[144] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៦ កថាខណ្ឌ១ ចំណុច ឃ។

[145] ដដែល, មាត្រា៧ កថាខណ្ឌ១។

[146] ដដែល, មាត្រា៧ កថាខណ្ឌ៣។

[147] ដដែល, មាត្រា៧ កថាខណ្ឌ៤។

[148] ដដែល, មាត្រា៧ កថាខណ្ឌ៦។

### ២.២.៣. កាតព្វកិច្ចរាយការណ៍ស្តីពីពន្ធដារ និងពន្ធគយ

បន្ទាប់ពីទទួលបានវិញ្ញាបនបត្រស្ថាពរ អ្នកវិនិយោគត្រូវមានកាតព្វកិច្ចរាយការណ៍ស្តីពី ពន្ធដារ និង ពន្ធគយ។[149] យោងតាមច្បាប់ស្តីពីសារពើពន្ធ អ្នកវិនិយោគត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធនោះ។[150] ការដាក់លិខិតប្រកាសពន្ធប្រចាំខែត្រូវធ្វើឡើងនៅថ្ងៃទី០១ ដល់ថ្ងៃទី២០ នៃខែបន្ទាប់ រីឯការប្រកាសពន្ធប្រចាំឆ្នាំត្រូវធ្វើឡើងនៅខែមីនាជារៀងរាល់ឆ្នាំ។[151] ចំពោះពន្ធគយវិញ អ្នកវិនិយោគមានកាតព្វកិច្ចរាយការណ៍ពីការលើកលែងនូវរាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់ដែលនាំចូលដោយគ.ល.គ.។

កាលបើអ្នកវិនិយោគបានបំពេញកាតព្វកិច្ចត្រឹមត្រូវក្នុងការធ្វើរបាយការណ៍សារពើពន្ធ និងពន្ធគយក.អ.ក. នឹងចេញនូវវិញ្ញាបនបត្របញ្ជាក់អំពីការបំពេញនូវកាតព្វកិច្ចចំពោះរដ្ឋ។[152] ផ្ទុយទៅវិញប្រសិនបើ ក.អ.ក. យល់ឃើញថាអ្នកវិនិយោគ មិនបានបំពេញកាតព្វកិច្ចបានត្រឹមត្រូវ ក.អ.ក. អាចដកហូតវិញ្ញាបនបត្របញ្ជាក់អំពីការបំពេញនូវកាតព្វកិច្ចចំពោះរដ្ឋ ហើយគ.ល.គ. របស់អ្នកវិនិយោគនឹងបាត់បង់ការលើកទឹកចិត្តវិនិយោគចាប់ពីថ្ងៃដកហូតវិញ្ញាបនបត្រនោះតទៅ។[153]

### ២.២.៤. កាតព្វកិច្ចស្នើសុំការយល់ព្រមផ្សេងៗរបស់ម្ចាស់គម្រោងវិនិយោគ

ការធ្វើសំណើរសុំជំនួស និងការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដោយ ក.អ.ក. មិនមានន័យថាជាការលើកលែងដល់អ្នកដាក់ពាក្យស្នើសុំ ចំពោះកាតព្វកិច្ចក្នុងការស្នើសុំការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីអនុវត្ត គ.ល.គ. ឱ្យមានដំណើរការស្របច្បាប់នោះទេ។[154] ដូច្នេះ ម្ចាស់ គ.ល.គ. នៅតែមានកាតព្វកិច្ចស្នើសុំជាលាយលក្ខណ៍អក្សរជូន ក.អ.ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត តាមនីតិវិធីច្បាប់នូវរាល់ការផ្លាស់ប្តូរ អាសយដ្ឋាន ទីស្នាក់ការ ការប្តូរទីតាំងអាជីវកម្ម ការប្តូរនាមករណ៍ ការប្តូរភាគហ៊ុន ឬការផ្លាស់ប្តូរព័ត៌មានលម្អិតផ្សេងៗនៅក្នុងសំណើរវិនិយោគ និងក្នុងលក្ខន្តិកៈរបស់ម្ចាស់គម្រោងវិនិយោគក្នុងរយៈពេល ១០ (ដប់) ថ្ងៃ។[155]

[149] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៧។

[150] ច្បាប់ស្តីពីសារពើពន្ធ, នស/រកម/០២៩៧/២៤, ២៤ កុម្ភៈ ១៩៩៧, មាត្រា ១០៤។

[151] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៧។

[152] ដដែល។

[153] ដដែល, មាត្រា១៨។

[154] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៧ កថាខណ្ឌ៥។

[155] ដដែល, មាត្រា៧ កថាខណ្ឌ៧។

### ២.២.៥. ការដកហូតគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

គ.ល.គ. នឹងត្រូវបានដកហូតមកវិញដោយ ក.អ.ក. ប្រសិនបើអ្នកវិនិយោគ (១) អលទ្ធភាពក្នុងការអនុវត្ត គ.ល.គ. (២) នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ (៣) ការខកខានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និង (៤) តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធលើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។[156]

បែបបទនៃការលុបចោល គ.ល.គ. មាននីតិវិធីផ្សេងៗគ្នាទៅតាមករណីនីមួយៗ។ នៅពេលដែលវិនិយោគិនគ្មានលទ្ធភាពក្នុងការអនុវត្ត គ.ល.គ. បន្តទៀត វិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិទៅ ក.អ.ក. ដោយលិខិតស្នើសុំនេះត្រូវមានចុះហត្ថលេខាដោយវិនិយោគិន ឬអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិត្រឹមត្រូវ ដោយមានបញ្ជាក់ពីមូលហេតុនៃអលទ្ធភាព និងភ្ជាប់មកជាមួយនូវឯកសារគាំទ្រផ្សេងៗ។ [157] ក្នុងករណីជាការរំលាយនីតិបុគ្គលវិញ ប្រសិនបើជាការរំលាយដោយការជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត[158] វិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិទៅក្រុមប្រឹក្សា ឬអនុគណៈកម្មធិការវិនិយោគរាជធានីខេត្ត។ [159] ប៉ុន្តែបើការរំលាយធ្វើឡើង តាមរយៈសេចក្តីសម្រេចរបស់តុលាការ [160] វិនិយោគិនត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចស្ថាពររបស់តុលាការ និងឯកសារពាក់ព័ន្ធអំពីការរំលាយនីតិបុគ្គល និងសេចក្តីបញ្ជាក់ពីទំនាក់ទំនងផលប្រយោជន៍ជាមួយ គ.ល.គ. បន្ថែមពីលើការដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ទៅ ក.អ.ក. ឬអនុគណៈកម្មាធិការរាជធានីខេត្ត។[161] ចំណែកឯករណីដែលវិនិយោគិនខកខានក្នុងការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នោះ ក.អ.ក. ឬអនុគណៈកម្មាធិការរាជធានីខេត្តមានសិទ្ធិអាចលុបចោល គ.ល.គ. តាមឆន្ទានុសិទ្ធិរបស់ខ្លួនបាន។[162]

---

[156] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ លេខ នស/រកម/០១៤, ១៥ តុលា ២០២១, មាត្រា៣១។

[157] ដដែល, មាត្រា៣២ កថាខណ្ឌ១។

[158] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥១-២៥៨។

[159] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ លេខ នស/រកម/០១៤, ១៥ តុលា ២០២១, មាត្រា៣២ កថាខណ្ឌ២។

[160] ច្បាប់ស្តីពីក្ស័យធន, លេខ លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា៦, ៧។

[161] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ លេខ នស/រកម/០១៤, ១៥ តុលា ២០២១, មាត្រា៣២ កថាខណ្ឌ៣។

[162] ដដែល, មាត្រា៣២ កថាខណ្ឌ៤។

កាលណាមានការដកហូតវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ក.អ.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកវិនិយោគអំពីការដកហូតនេះ។[163] ជាលទ្ធផលនៃការដកហូត គ.ល.គ. នឹងមិនទទួលបានការលើកទឹកចិត្ត ដូចមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរគិតចាប់ពីកាលបរិច្ឆេទនៃការដកហូត ឬលុបចោលតទៅ។[164]

## ២.៣. ទម្រង់សម្ព័ន្ធអាជីវកម្មនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

បន្ថែមពីការស្នើសុំ គ.ល.គ. អ្នកវិនិយោគក៏អាចទិញ គ.ល.គ. ពីនីតិបុគ្គលផ្សេងទៀតបានដែល។ ទម្រង់នៃការទិញ គ.ល.គ. អាចជា (**២.៣.១**) ការរំលាយចូលគ្នានៃគ.ល.គ. និង (**២.៣.២**) ការទិញភាគហ៊ុនពីនីតិបុគ្គលដែលមានគ.ល.គ.។

### ២.៣.១. ការរំលាយចូលគ្នានៃគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

ប្រសិនបើអ្នកវិនិយោគពីរ ឬច្រើន ឬអ្នកវិនិយោគ និងជនណាមួយ បានព្រមព្រៀងរំលាយបញ្ចូលគ្នាក្នុងការបង្កើតនីតិបុគ្គលថ្មី ហើយនីតិបុគ្គលថ្មីនោះមានបំណងចង់អនុវត្ត គ.ល.គ. របស់អ្នកវិនិយោគដែលមានការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ដូចមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរនៃ គ.ល.គ. នីតិបុគ្គលថ្មីនោះត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅ ក.អ.ក. ដើម្បីចុះបញ្ជី និងស្នើសុំការផ្ទេរវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរនៃ គ.ល.គ. មកឱ្យនីតិបុគ្គលថ្មីនេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការមុននឹងធ្វើការរំលាយបញ្ចូលគ្នា និងធ្វើការផ្ទេរវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។[165] ក.អ.ក. នឹងពិនិត្យលើពាក្យស្នើសុំ និងសម្រេចថាយល់ព្រម ឬបដិសេធលើការចុះបញ្ជីក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំនោះ។[166]

### ២.៣.២. ការទិញយកគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

ប្រសិនបើបុគ្គលដែលមានបំណងទិញយក គ.ល.គ. របស់អ្នកវិនិយោគផ្សេងទៀតដែលទទួលបានការលើកទឹកចិត្ត និងការធានាលើការវិនិយោគដូចមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពររបស់អ្នកវិនិយោគនោះ អ្នកវិនិយោគដែលជាអ្នកទិញត្រូវគោរពតាមនីតិវិធីពីរដូចតទៅ៖[167] (១) រាល់ប្រតិបត្តិការទិញលក់ គ.ល.គ. អាចប្រព្រឹត្តទៅបាន លុះត្រាតែអ្នកវិនិយោគនៅក្នុងនីតិបុគ្គលដែលទទួលគ.ល.គ. បានកាន់កាប់ភាគហ៊ុនយ៉ាងតិច

---

[163] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៨ កថាខណ្ឌ៣។

[164] ដដែល, មាត្រា៨ កថាខណ្ឌ៥។

[165] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា ៩(១)។

[166] ដដែល, មាត្រា៩(២)។

[167] ដដែល, មាត្រា១០,១១។

២០ (ម្ភៃ) ភាគរយ[168] (២) ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅ ក.អ.ក. តាមនីតិវិធីចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការផ្ទេរវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។[169]

ក.អ.ក. នឹងពិនិត្យលើពាក្យស្នើសុំ និងសម្រេចថាយល់ព្រម ឬបដិសេធនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនបត្រការចុះបញ្ជីជាស្ថាពរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំនោះ។[170] រាល់ការខកខានក្នុងការចុះបញ្ជីវិនិយោគ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញ មិនមានសិទ្ធិទទួលបានការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយនៃ គ.ល.គ. ឡើយ។[171] ផ្ទុយទៅវិញប្រសិន បើអ្នកវិនិយោគដែលជាអ្នកទិញខកខានមិនបានស្នើសុំមកក.អ.ក. ឬអ.វ.គទេ អ្នកវិនិយោគដែលជាអ្នកទិញមិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់គ.ល.គ.។[172]

[168] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា ៩(១)។
[169] ដដែល។
[170] ដដែល។
[171] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១០,១១។
[172] ដដែល។

# ជំពូកទី៣
# ឥទ្ធិពល និងផលជះនៃគម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ច កម្ពុជា

# ជំពូកទី៣៖ ឥទ្ធិពល និងផលជះនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់លើសេដ្ឋកិច្ចកម្ពុជា

## ៣.១. គុណសម្បត្តិ

សេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមមានការរីកចម្រើនចាប់ពីចុងទស្សវត្សរ៍ឆ្នាំ ១៩៩០ ដោយសារស្ថេរភាពនយោបាយនៅក្នុងប្រទេស និងគោលនយោបាយគាំទ្រការវិនិយោគពីបរទេសរបស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់ការលើកទឹកចិត្តដល់សហគ្រាសបរទេសដូចជា ការលើកលែងពន្ធ ពន្ធគយចំពោះការនាំចូលសម្ភារៈបរិក្ខារ និងវត្ថុធាតុដើមនានា។[173] ការលើកទឹកចិត្ត គួបផ្សំនឹងកម្លាំងពលកម្មដែលមានភាពវ័យក្មេង និងតម្លៃទាប គឺជាមូលហេតុមួយដែលទាក់ទាញវិនិយោគិនពីបណ្តាប្រទេសជាច្រើនដូចជា ចិន ហុងកុង តៃវ៉ាន់ កូរ៉េខាងត្បូង ម៉ាឡេស៊ី និងសិង្ហបុរីមកវិនិយោគ និងបង្កើតរោងចក្រនៅកម្ពុជា។[174] លំហូរនៃការវិនិយោគទាំងនេះបានជំរុញដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា ទៅលើវិស័យចម្បងទាំង៤ រួមមាន (**៣.១.១.**) វិស័យកសិកម្ម (**៣.១.២.**) វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង (**៣.១.៣.**) វិស័យទេសចរណ៍ និង (**៣.១.៤.**) វិស័យសំណង់។

### ៣.១.១. វិស័យកសិកម្ម

វិស័យកសិកម្មជាវិស័យដ៏សំខាន់មួយ ដែលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយសារកម្ពុជាគឺជាប្រទេសដែលសម្បូរទៅដោយធនធានធម្មជាតិ និងដីមានជីជាតិល្អ ដែលផ្តល់អំណោយផលដល់ការធ្វើកសិកម្ម។ ប្រជាជនប្រមាណជា ៨០% ដែលរស់នៅជនបទ ពឹងផ្អែកជាចម្បងលើការធ្វើកសិកម្ម ដើម្បីផ្គត់ផ្គង់ស្បៀងអាហារ បង្កើនប្រាក់ចំណូល និងលើកកម្ពស់កម្រិតជីវភាពរស់នៅក្នុងគ្រួសារ។[175] បើទោះបីជាកសិកម្មបានផ្តល់ឱកាសការងារ ក៏ដូចជាចំណូលសម្រាប់ចិញ្ចឹមជីវិតរបស់ប្រជាកសិករនៅទីជនបទ ចាប់ពីឆ្នាំ ១៩៩១ រហូតមកដល់ ២០១៧ ឱកាសការងារក្នុងវិស័យកសិកម្មមានការធ្លាក់ចុះដោយសារតែការរីកចម្រើននូវវិស័យវាយនភណ្ឌ វិស័យឧស្សាហកម្ម និងការរីកចម្រើននៃវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចជាដើម ជាហេតុជំរុញ

---

[173] អង្គការពលកម្មអន្តរជាតិ, *ការស្រាវជ្រាវផ្តោតលើសកម្មភាពអំពីសមភាពយេនឌ័រ និងលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករនិយោជិតរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា* (ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក, ២០១២), ២២។

[174] ដដែល។

[175] Saing, Chan Hang, Hem Socheth, Ouch Chandarany, and Pon Dorina, *Foreign Investment in Agriculture in Cambodia* [ការវិនិយោគពីបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា] (Cambodia's Leading Independent Development Policy Research Institute, 2012), 8។

ឱ្យប្រជាពលរដ្ឋមួយចំនួនបានឈប់ធ្វើកសិកម្ម និងមកចាប់ឱកាសការងារថ្មីក្នុងវិស័យទាំងនេះវិញ។[176] យ៉ាងណាមិញ វិស័យកសិកម្មនៅតែបន្តជ្រោមជ្រែង និងអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរីកចម្រើនបន្តទៅទៀត។ ហេតុដូច្នេះហើយទើបរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយ ដើម្បីជំរុញដល់ការវិនិយោគក្នុងវិស័យកសិកម្មនៅកម្ពុជា។[177] តាមរយៈការលើកទឹកចិត្ត និងដាក់វិធានការមិនយកអាករនាំចូលចំពោះគ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត និងបរិក្ខារ ឧបករណ៍ ឬគ្រឿងបច្ចេកទេសកសិកម្មផ្សេងៗ។[178] បន្ថែមពីនេះ រាជរដ្ឋាភិបាលបានផ្ដល់ការលើកលែងពន្ធអាការចាប់ពី ៣ឆ្នាំ រហូតដល់ ៩ ឆ្នាំ។[179] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចាត់ថ្នាក់គម្រោងវិនិយោគនៅក្នុងវិស័យកសិកម្ម ដែលទទួលបានការលើកលែងពន្ធអាករ ចំនួនបួនធំៗរួមមាន ១) ផលិតកម្មកសិកម្ម ២) ផលិតកម្មបសុសត្វ ៣) ផលិតកម្មជលផល និង ៤) ការដាំឈើ រុក្ខជាតិ ការចិញ្ចឹមសត្វព្រៃផ្សេងៗ។[180] ផលិតកម្មកសិកម្មដែលមានការនាំចេញច្រើនជាងគេនៅកម្ពុជា មានដូចជាផលិតផលដំណាំ ផលិតកម្មសត្វ ជលផល ផលិតផល ព្រៃឈើ និងកៅស៊ូ។[181] រហូតមកដល់ត្រឹមឆ្នាំ ២០២១ តម្លៃនៃការនាំចេញផលិតកម្មកសិកម្មសរុបមានទំហំ ៥,០០០ លានដុល្លារអាមេរិក ដែលកើនឡើងប្រមាណជា ២៥% បើធៀបទៅនឹងការនាំចេញផលិតកម្មកសិកម្មសរុបក្នុងឆ្នាំ២០២០។[182] នេះបញ្ជាក់ថាវិស័យកសិកម្មនៅតែជាវិស័យស្នូលមួយដែលបម្រើដល់ការនាំចេញរបស់កម្ពុជា។

### ៣.១.២. វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង

វិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ទទួលបានការរីកចម្រើន និងទាញយកផលប្រយោជន៍បានច្រើនជាងគេពីការវិនិយោគដោយផ្ទាល់ពីបរទេសនៅកម្ពុជា ដោយសារតម្លៃកម្លាំងពលកម្មទាប គួបផ្សំនឹងការទទួលបានការអនុគ្រោះពន្ធពីទីផ្សារបស្ចឹមប្រទេសដែលមានជាអាទិ៍ សហភាពអឺរ៉ុប អាមេរិក កាណាដា និងចក្រ

[176] ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន, លេខ នស/រកម/១០០៩/០២០, ២២ តុលា ឆ្នាំ ២០០៩, មាត្រា ៣។

[177] Hem, Sochet, *Foreign Investment in Agriculture in Cambodia: A survey of recent trends* [ការវិនិយោគពីបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា៖ ការពិនិត្យលើនិន្នាការថ្មីៗ] (Trade Knowledge Network, 2012), 7។

[178] ដដែល។

[179] ដដែល។

[180] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី ១។

[181] ក្រសួងកសិសកម្ម រុក្ខប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ២០២២* (ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ, ២០២២), ២៩។

[182] ដដែល, ២៣។

ភាពអង់គ្លេសជាដើម។[183] មកទល់ពេលបច្ចុប្បន្នវិស័យកាត់ដេរ និងស្បែកជើងនៅតែជាក្បាលម៉ាស៊ីនដ៏សំខាន់ចំពោះកំណើនសេដ្ឋកិច្ចកម្ពុជាដោយតំណាងឱ្យប្រមាណជា ៨០% នៃការនាំចេញសរុប។[184] ទីផ្សារនាំចេញចម្បងរបស់កម្ពុជាគឺ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ការនាំចេញនៃសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាទៅសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៩ មានតម្លៃប្រមាណជា ៣៤៣០ លានដុល្លារអាមេរិក និងទៅសហភាពអឺរ៉ុបក្នុងតម្លៃ ៣២៤៩ លានដុល្លារអាមេរិក[185] ដែលស្មើនឹង ៧៣.៤% នៃការនាំចេញសរុបរបស់កម្ពុជាក្នុងឆ្នាំដដែល។[186] ដោយឡែកការនាំចេញនៅក្នុងឆ្នាំ ២០២០ មានការធ្លាក់ចុះជាងពាក់កណ្ដាលដោយសារការរីករាលដាលនៃជម្ងឺកូវីដ-១៩ នៅសល់ត្រឹម ១,៦៤០ លាន ដុល្លារអាមេរិកសម្រាប់សហរដ្ឋអាមេរិក និង ១,២៨៦ លានដុល្លារអាមេរិកសម្រាប់សហភាពអឺរ៉ុប ។[187] ទោះជាយ៉ាងនេះក្ដី នៅក្នុងឆ្នាំ ២០២១ ការនាំចេញនៃផលិតផលកាត់ដេររបស់កម្ពុជាមានតម្លៃសរុបប្រមាណជា ១១,៣៤០ លានដុល្លារអាមេរិក[188] ដែលវិស័យនេះមានការងើបឈរឡើងវិញយ៉ាងឆាប់រហ័សថ្វីត្បិតតែទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ និងការដកហូតប្រព័ន្ធអនុគ្រោះពន្ធដោយសហភាពអឺរ៉ុបក្ដី។ ទន្ទឹមនឹងការបង្កើតប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិ វិស័យនេះបានរួមចំណែកមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ នៅក្នុងឆ្នាំ ២០០៨ វិស័យនេះបានបង្កើតការងារដល់ប្រជាជនប្រមាណ ៣៥០,០០០ នាក់ ស្មើនឹង ៤% នៃកម្លាំងពលកម្មសរុប។[189] មកដល់ឆ្នាំ ២០១៦ វិស័យនេះ

---

[183] អង្គការពលកម្មអន្តរជាតិ, *ការស្រាវជ្រាវផ្តោតលើសកម្មភាពអំពីសមភាពយេនឌ័រ និងលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករនិយោជិតរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា* (ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក, ២០១២), ២២។

[184] Arnold, Dennis, *Cambodia's Garment Sector in Transformation: External Shocks, Political Space, and Supplier Consolidation* [បំលាស់ប្តូរនៃវិស័យកាត់ដេរនៅកម្ពុជា៖ ឥទ្ធិពលខាងក្រៅ បញ្ហានយោបាយ និង ការប្រកួតប្រជែងរវាងអ្នកផ្គត់ផ្គង់] (CNV International, 2021), 7។

[185] Nuon, Veasna, *Mapping Social Dialogue in Apparel: Cambodia* [ការតភ្ជាប់កិច្ចសន្ទនាសង្គមក្នុងវិស័យកាត់ដេរ៖ កម្ពុជា] (ILR New Conversations Project, 2021), 6។

[186] Edge, Abby និង Sheng Lu, How will EU trade curb affect Cambodia's apparel industry? [ការតភ្ជាប់កិច្ចសន្ទនាសង្គមក្នុងវិស័យកាត់ដេរ៖ កម្ពុជា] (JustStyle, 2020)។

[187] Nuon, Veasna, *Mapping Social Dialogue in Apparel: Cambodia* [ការតភ្ជាប់កិច្ចសន្ទនាសង្គមក្នុងវិស័យកាត់ដេរ៖ កម្ពុជា] (ILR New Conversations Project, 2021), 6។

[188] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ពិតជាធ្វើឲ្យវិស័យនេះ មាននិរន្តរភាព បន្តរីកចម្រើនទៅមុខទៀត, អាចរកបាននៅ https://bit.ly/3SsPT6n (ទសន្សនាចុងក្រោយថ្ងៃទី២៩ កក្កដា ២០២២)។

[189] Chan, Sophal និង Sothea Oum, *Impact of garment and textile trade preferences on livelihoods in Cambodia* [ផលវិបាកនៃវិស័យកាត់ដេរ និងវាយនភណ្ឌលើជីវភាពរស់នៅនៅកម្ពុជា] (Oxfam America Research Backgrounders Series, 2011), 9។

បានផ្តល់ការងារក្នុងចំនួនទ្វេរដង គឺប្រមាណជា ៦០៥,១២៩ កន្លែងដែលស្មើនឹង ៧.៣% នៃកម្លាំងពលកម្មសរុប។[190] រហូតមកដល់ឆ្នាំ ២០១៩ វិស័យនេះបានផ្តល់ការងារដល់ប្រជាជនរហូតដល់ទៅ ៩៤១,000 នាក់ ដែលស្មើនឹង ១០.៧% នៃកម្លាំងពលកម្មសរុប។[191] ប្រាក់ចំណូលរបស់កម្មករកម្មានីរោងចក្រ គឺជាប្រាក់ចំណូលចម្បងសម្រាប់ទ្រទ្រង់ការចំណាយប្រចាំថ្ងៃរបស់គ្រួសារពួកគេនៅឯជនបទ។ សមាជិកគ្រួសារពួកគេពឹងផ្អែកលើប្រាក់នេះដើម្បីផ្គត់ផ្គង់ការសិក្សាអប់រំរបស់បងប្អូន ចំណាយលើសេវាសុខភាព និងសម្រាប់សងបំណុលជាដើម។[192] លើសពីនេះ បណ្តាអ្នកលក់ដូរម្ហូបអាហារ ភេសជ្ជៈ និងសម្ភារៈប្រើប្រាស់នានាជុំវិញទីតាំងរោងចក្រក៏ទទួលបានប្រយោជន៍សេដ្ឋកិច្ចដូចគ្នាពីការធ្វើអាជីវកម្មនៅជុំវិញទីតាំងរោងចក្រ ដែលជាការរួមចំណែកមួយក្នុងការបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា។[193]

### ៣.១.៣. វិស័យទេសចរណ៍

ប្រទេសកម្ពុជាមានវប្បធម៌ និង អារិយធម៌ចំណាស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយទឹកដីកម្ពុជាសម្បូរទៅដោយតំបន់ទេសចរណ៍ធម្មជាតិ និងស្ថាបត្យកម្មដ៏ល្អឯក ដែលសុទ្ធតែជាមូលហេតុសំខាន់ៗក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ទាំងក្នុងស្រុក និងក្រៅប្រទេស។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារវិស័យនេះបង្កើតកាលនុវត្តភាពការងារ បង្កើតប្រាក់ចំណូល និងលើកកម្ពស់ដល់ជីវភាពរស់នៅប្រជាពលរដ្ឋ ព្រមទាំងទាក់ទាញដល់ការវិនិយោគដោយផ្ទាល់ពីបរទេស និងជាប្រភពចំណូលមួយនៃរូបិយប័ណ្ណអន្តរជាតិ ដែលសុទ្ធសឹងតែជាកត្តាសំខាន់ៗសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ។[194] ក្នុងឆ្នាំ ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ «ការត្រៀមលក្ខណៈដើម្បីទេសចរណ៍ចិន» ដែលជាភាសាអង់គ្លេសហៅថា China Ready

---

[190] International Labor Organization, *What explains strong export and weak employment figures in the Cambodian garment sector?* [តើអ្វីជាមូលហេតុនៃការនាំចេញច្រើន និងអត្រាពលកម្មទាបក្នុងវិស័យកាត់ដេរនៅកម្ពុជា ?] (Cambodia Garment and Footwear Sector Bulletin, 2017), 8។

[191] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 4។

[192] អង្គការពលកម្មអន្តរជាតិ, ការស្រាវជ្រាវផ្តោតលើសកម្មភាពអំពីសមភាពយេនដ័រ និងលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករនិយោជិតរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា (ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក, ២០១២), ២១។

[193] Arnold, Dennis, ***Cambodia's Garment Sector** in Transformation: External Shocks, Political Space, and Supplier Consolidation* [បំលាស់ប្តូរនៃវិស័យកាត់ដេរនៅកម្ពុជា៖ ឥទ្ធិពលខាងក្រៅ បញ្ហានយោបាយ និង ការប្រកួតប្រជែងរវាងអ្នកផ្គត់ផ្គង់] (CNV International, 2021), 4។

[194] ហ៊ុន សែន, សារលិខិតរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសទិវាទេសចរណ៍ពិភពលោកក្រោមប្រធានបទ «និរន្តរភាពទេសចរណ៍ ជាយន្តការសម្រាប់ការអភិវឌ្ឍ», ២៧ កញ្ញា ២០១៧, ២។

Policy។[195] គោលនយោបាយនេះទទួលបានជោគជ័យយ៉ាងខ្លាំង ដោយមានការភ្ជាប់ជើងហោះហើរត្រង់ថ្នាក់តំបន់ពីចិនមកកម្ពុជា និងការទាក់ទាញទេសចរចិនតាមរយៈការផ្តល់សេវាកម្មជាភាសាចិនដូចជា ការប្រើប្រាស់បុគ្គលិកដែលចេះភាសាចិនអាចសន្ទនាជាមួយទេសចរ បន្ថែមភាសាចិនក្នុងបញ្ជីមុខម្ហូបតាមភោជនីយដ្ឋាន បន្ថែមស្លាកសញ្ញាដែលមានភាសាចិនជាដើម។[196] ជាហេតុនាំឱ្យទេសចរចិនស្ថិតនៅក្នុងលំដាប់ថ្នាក់ទី១ នៃភ្ញៀវទេសចរអន្តរជាតិដែលចូលមកប្រទេសកម្ពុជា ដែលមានចំនួនដល់ទៅជិត ២,៤ លាននាក់ក្នុងឆ្នាំ ២០១៩។[197] ក្នុងឆ្នាំ ២០១៩ វិស័យទេសចរណ៍បានទាញយកចំណូលចំនួនប្រមាណជា ៤៩០០ លាន ដុល្លាអាមេរិក ពីភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ៦,៦ លាននាក់។[198] ក្នុងឆ្នាំដដែល វិស័យនេះបានបង្កើតការងារចំនួន ៦២០,០០០ កន្លែង ដែលជាវិស័យស្រូបយកកម្លាំងពលកម្មធំជាងគេទីពីរបន្ទាប់ពីវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។[199] ប្រជាជនដែលរស់នៅជុំវិញតំបន់ទេសចរណ៍ទទួលបានប្រយោជន៍សេដ្ឋកិច្ចពីការចំណាយរបស់អ្នកទេសចរទៅលើទីកន្លែងស្នាក់នៅ ចំណីអាហារ និងភេសជ្ជៈ មធ្យោបាយធ្វើដំណើរ ការលក់វត្ថុអនុស្សាវរីយ៍ជាអាទិ៍។

### ៣.១.៤. វិស័យសំណង់

វិស័យសំណង់ បានក្លាយជាវិស័យចម្បងដែលជំរុញដល់កំណើនផលិតផលក្នុងស្រុកសរុបចាប់ពីឆ្នាំ ២០១៥ ដែលផ្តល់អត្រាកំណើន ៧.១% ក្នុងចន្លោះឆ្នាំ ២០១៥ ដល់ ២០១៩។[200] គម្រោងវិនិយោគអចលនទ្រព្យជាពិសេសគម្រោងអចលនទ្រព្យលើអគារពាណិជ្ជកម្ម សំណង់លំនៅដ្ឋានទំនើបទាន់សម័យ សំណង់បុរី និងអគារផ្សេងៗមានការរីកចម្រើនគួរឱ្យកត់សម្គាល់។[201] នៅក្នុងឆ្នាំ ២០១៩ ការវិនិយោគលើវិស័យនេះមានតម្លៃ

---

195 ក្រុមធនាគារពិភពលោក, *បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ ប្រទេសកម្ពុជាបានកើនឡើងនូវខ្សែសង្វាក់ផលិតកម្ម* (ទីក្រុងវ៉ាស៊ីនតោន៖ ធនាគារពិភពលោក,២០១៨), ៧។

196 Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham), 36។

197 ដដែល។

198 ដដែល។

199 ដដែល។

200 United Nations Cambodia, *Cambodia Common Country Analysis: Towards an Inclusive, Equitable and Sustainable Recovery* [ការវិភាគជារួមលើកម្ពុជា៖ ឆ្ពោះទៅកាន់ការស្តារសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន សមធម៌ និងនិរន្តភាព] (Phnom Penh: United Nations Country Team Cambodia, 2021), 10។

201 Eurocham, Business Opportunities in Cambodia: Investment Information [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham, 2021), 39។

ដល់ទៅប្រមាណជា ១១,៤ ពាន់លានដុល្លារអាមេរិក[202] នេះជាការកើនឡើងយ៉ាងខ្ពស់បើធៀបនឹងតម្លៃ ៣,៣ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ ២០១៥ និង ៦,៨ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៦។[203] គម្រោងវិនិយោគទាំងនេះភាគច្រើនជាការវិនិយោគដោយផ្ទាល់ពីបរទេស ដែលក្នុងនោះមាន ចិន ចំនួន ៤៣% កូរ៉េចំនួន ១១% វៀតណាមចំនួន ៧% សិង្ហបុរី និងជប៉ុនចំនួន ៦% និង បណ្ដាប្រទេសដទៃទៀតចំនួន ២៧%។[204] ដោយមើលឃើញពីសម្ទុះរីកចម្រើនយ៉ាងសន្ទឹកក្នុងវិស័យអចលនទ្រព្យ និងសំណង់ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តក្នុងការទាក់ទាញការវិនិយោគ ដោយការដាក់ចេញនូវយន្តការជាច្រើន រួមមានការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធនានា និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។[205] លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានរំពឹងថា ការដាក់ចេញនូវច្បាប់វិនិយោគថ្មី ២០២១ នឹងធ្វើឱ្យបរិយាកាសវិនិយោគនៅកម្ពុជាកាន់តែប្រសើរឡើង និងអាចទាក់ទាញការវិនិយោគបានកាន់តែច្រើន។[206]

### ៣.២. បញ្ហាប្រឈម

សេដ្ឋកិច្ចកម្ពុជាហាក់ពឹងផ្អែកខ្លាំងលើវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ទេសចរណ៍ សំណង់ និងកសិកម្មជាពិសេសទៅលើការនាំចេញស្រូវអង្ករ។ ការពឹងពាក់នេះ បណ្ដាលឱ្យសេដ្ឋកិច្ចកម្ពុជាមានភាពទន់ខ្សោយ និងងាយរងគ្រោះពីបម្រែបម្រួលនៃលក្ខខណ្ឌពាណិជ្ជកម្ម។ ជាក់ស្ដែងទៅលើបញ្ហាមួយចំនួនដូចជាតម្រូវការទីផ្សាររបស់ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ព្រមទាំងប្រឈមនឹងការប្រកួតប្រជែងពីប្រទេសដទៃដែលមានតម្លៃពលកម្មទាប និងសមត្ថភាពផលិតកម្មខ្ពស់ជាងកម្ពុជា។[207] តួយ៉ាងចាប់តាំងពីឆ្នាំ ២០២០ មក សេដ្ឋកិច្ចកម្ពុជាទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិកូវីដ-១៩ ដែលគម្រោងវិនិយោគមួយចំនួនធំបានផ្អាកដំណើរការ រោងចក្របិទទ្វារ ប្រជាពលរដ្ឋបាត់បង់ការងារ បាត់បង់ប្រភពចំណូល ចំណូលសេដ្ឋកិច្ចជាតិពីការ

---

[202] Eurocham, Business Opportunities in Cambodia: Investment Information [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham, 2021), 39។

[203] World Bank Group, *Enhancing Export Competitiveness: The Key to Cambodia's Future Economic Success* [ការលើកកម្ពស់ការប្រកួតប្រជែងក្នុងការនាំចេញ៖ គន្លឹះនៃភាពជោគជ័យរបស់សេដ្ឋកិច្ចកម្ពុជានាពេលអនាគត] (World Bank, 2016), 8។

[204] Eurocham, *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ] (Phnom Penh: Eurocham, 2021), 14។

[205] ដដែល។

[206] ដដែល។

[207] Asian Development Bank, *Cambodia: Diversifying Beyond Garments and Tourism* [កម្ពុជា៖ ការធ្វើពិពិធកម្មលើសពីវិស័យកាត់ដេរ និងទេសចរណ៍] (Phillipines: Asian Development Bank, 2014), 103។

ប្រមូលពន្ធត្រូវបានធ្លាក់ចុះដោយសារគម្រោងវិនិយោគត្រូវបានបិទទ្វា ឬផ្អាកដំណើរការ។[208] ជាមួយគ្នានេះដែរ វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ទេសចរណ៍ និងសំណង់ ដែលជាវិស័យស្នូលនៃសេដ្ឋកិច្ចកម្ពុជាក៏ទទួលរងគ្រោះពីវិបត្តិកូវីដ-១៩ ផងដែរ។

វិស័យកាត់ដេរ និងស្បែកជើង បានរងគ្រោះ និងមានបញ្ហាប្រឈមខ្លាំងផងដែរ អំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩។ ចង្វាក់ផលិតកម្ម និងការនាំចេញ ត្រូវបានកាត់ផ្តាច់ ជាពិសេសការនាំចេញទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ត្រូវបានបង្អក ឬលុបចោល។[209] ក្នុងឆ្នាំ ២០២០ រោងចក្រកាត់ដេរ ៥០៦ ក្នុងចំណោម ១,០៨៧ បានផ្អាកដំណើរការពាក់កណ្តាល ឬស្ទើរតែទាំងស្រុង ដែលបានជះឥទ្ធិពលដល់កម្មករនិយោជិតចំនួន ៣២៣,៦៧៤ នាក់ដែលស្មើនឹង ៣៤% នៃចំនួនពលកម្មសរុបនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់។[210] លើសពីនេះ រោងចក្រកាត់ដេរចំនួន ១២៩ បានបិទដំណើរការតែម្តង ហើយឈានដល់ការបញ្ឈប់កម្មករនិយោជិតចំនួន ៧១,២០២ នាក់។[211] ចំណែករោងចក្រស្បែកជើងជាង ១៣០ រោងចក្រ ដែលស្មើនឹង ១២ ភាគរយ នៃចំនួនរោងចក្រសរុបក៏បានផ្អាកដំណើរការចាប់តាំងពីពាក់កណ្តាលខែមេសានៃឆ្នាំ ២០២០ ជាលទ្ធផលកម្មករនិយោជិតប្រមាណជា ១០០,០០០ នាក់បានបាត់បង់ការងារធ្វើ។[212]

វិស័យទេសចរណ៍គឺជាវិស័យដែលរងគ្រោះខ្លាំងជាងគេ និងបានដួលរលំក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩។ ដើម្បីទប់ស្កាត់ការរីករាលដាលនេះ រាជរដ្ឋាភិបាលកម្ពុជាបានរឹតបណ្តឹងការធ្វើដំណើរគ្រប់ច្រកល្ហកទាំង ផ្លូវគោក ផ្លូវអាកាស និងផ្លូវទឹក[213] និងឈានដល់ការបិទព្រំដែនតែម្តងនៅអំឡុងខែមេសា ឆ្នាំ២០២១។ ខេត្តសៀមរាប ដែលជាតំបន់ទេសចរណ៍ដ៏ពេញនិយមមួយរបស់កម្ពុជា បានបាត់បង់ភ្ញៀវទេសចរណ៍រហូតដល់ ៤៥.៦% ក្នុងអំឡុងពេលត្រីមាសទី ១ និង ៩៩.៦% ក្នុងខែមេសា ឆ្នាំ២០២០។[214] ការធ្លាក់ចុះក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច បានធ្វើឱ្យអាជីវកម្មបម្រើដល់ទេសចរណ៍ដូចជា ភោជនីយដ្ឋាន សណ្ឋាគារ

---

[208] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 11។

[209] ដដែល, 4។

[210] United Nations Cambodia, *Cambodia Common Country Analysis: Towards an Inclusive, Equitable and Sustainable Recovery* [ការវិភាគជារួមលើកម្ពុជា៖ ឆ្ពោះទៅកាន់ការស្តារសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន សមធម៌ និងនិរន្តភាព] (Phnom Penh: United Nations Country Team Cambodia, 2021), 13។

[211] ដដែល, 14។

[212] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 4។

[213] ដដែល, 12។

[214] ដដែល។

រមណីយដ្ឋាន និងកន្លែងកម្សាន្តផ្សេងៗ ចំនួន ២,៨៦៥ កន្លែងផ្អាកដំណើរការ និងបិទទ្វារ បើធៀបទៅនឹងទីតាំងអាជីកម្មទេសចរណ៍សរុបចំនួន ៩,៦៨៩ ទូទាំងប្រទេស។[215] ជាលទ្ធផលប្រជាពលរដ្ឋប្រមាណជា ៦២០.០០០ នាក់បាត់បង់ការងារ និងប្រាក់ចំណូល។[216] មិនតែប៉ុណ្ណោះ ប្រជាពលរដ្ឋដែលប្រកបរបរក្នុងលក្ខណៈជាសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលរួមមាន អ្នករត់ម៉ូតូកង់បី អាជីវករលក់ដូរតាមតំបន់ទេសចរណ៍ដូចជា ខេត្តសៀមរាប និងខេត្តព្រះសីហនុប្រឈមនឹងកង្វះខាតថវិកាដោយសារបាត់បង់ប្រភពចំណូលផងដែរ។[217]

សកម្មភាពសំណង់មួយផ្នែកធំពឹងផ្អែកលើហិរញ្ញប្បទានពីការវិនិយោគដោយផ្ទាល់ពីបរទេសជាពិសេសពីប្រទេសចិនផ្ទាល់។[218] ហេតុដូច្នេះហើយ គម្រោងសាងសង់ធំៗជាច្រើននៅកម្ពុជាត្រូវបានផ្អាកដំណើរការដោយសារតែវិនិយោគិនទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។ ជាលទ្ធផលនាំឱ្យរដ្ឋបាត់បង់ប្រភពចំណូលយ៉ាងសំខាន់មួយ ដោយសារវិស័យសំណង់ចូលរួមបង្កើតប្រាក់ចំណូលដល់រដ្ឋតាមរយៈពន្ធគយសម្រាប់ការនាំចូលសម្ភារៈសំណង់ជាពិសេសទៅលើដែកថែប និងស៊ីម៉ង់។[219] ការនាំចូលដែកថែប និងស៊ីម៉ង់ដែលបម្រើដល់ការ សាងសង់បានធ្លាក់ចុះ ៤៧.៦% នាបីខែដំបូងនៃដើមឆ្នាំ ២០២០។[220] តម្លៃនៃការនាំចូលទៅលើសម្ភារៈសំណង់បានថយចុះសល់ត្រឹម ១៧៩ លានដុល្លាអាមេរិក បើធៀបនឹងតម្លៃ ២០៤ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៨។[221] ទោះយ៉ាងនេះក្ដី វិស័យសំណង់ត្រូវបានប៉ាន់ស្មានថានឹងមិនផ្ដល់ផលប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ចសង្គមឡើយ បើធៀបទៅនឹងការធ្លាក់ចុះក្នុងវិស័យវាយនភណ្ឌ និងទេសចរណ៍ ដោយសារវិស័យសំណង់ផ្ដល់ការងារធ្វើជូនប្រជាពលរដ្ឋប្រមាណជា ២០០,០០០ កន្លែងប៉ុណ្ណោះ។[222]

ថ្វីបើវិស័យកសិកម្មពុំទទួលរងឥទ្ធិពលអាក្រក់ពីជម្ងឺកូវីដ-១៩ បើធៀបនឹងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ក្ដី វិស័យកសិកម្មនៅតែជួបប្រទះនឹងបញ្ហាមួយចំនួនដែលរាំងស្ទះដល់ការបង្កើនផលិតកម្ម។ ការប្រែប្រួលអាកាសធាតុ និងកត្តាបច្ចេកទេសក្នុងការផលិត គឺជាបញ្ហាចម្បងដែលវិស័យកសិកម្មកំពុងជួប

---

[215] ហេង, សុភី, *សេដ្ឋកិច្ច និងទេសចរណ៍កម្ពុជាក្នុងដំណាក់កាលជម្ងឺកូវីដ១៩* (ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា, ២០២០), ៤។

[216] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 20។

[217] ហេង, សុភី, *សេដ្ឋកិច្ច និងទេសចរណ៍កម្ពុជាក្នុងដំណាក់កាលជម្ងឺកូវីដ១៩* (ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា, ២០២០), ៥។

[218] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 18។

[219] ដដែល, 18។

[220] ដដែល, 17។

[221] ដដែល។

[222] ដដែល។

ប្រទះ។[223] កត្តាបម្រែបម្រួលអាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ បានវាយលុកមកលើផលិតកម្មដំណាំកសិកម្ម សត្វ និងជលផល ជាហេតុនាំឱ្យផលិតភាពកសិកម្មដែលកំពុងមានកម្រិតកាន់តែថយចុះបន្ថែមទៀត។[224] រនាំងនៃការបង្កើនផលិតភាពកសិកម្មនៅកម្ពុជា គឺភាពខ្វះខាតនៃការផ្ទេរបច្ចេកទេសកសិកម្មទំនើប ដែលបច្ចេកទេសក្នុងការធ្វើកសិកម្មបច្ចុប្បន្នពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ដែលអាចឆ្លើយតបនឹង សេចក្ដីត្រូវការជាក់ស្ដែងបានឡើយ។ កង្វះនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មកសិកម្មដូចជា ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋាន ឧបករណ៍ក្នុងការដាំដុះ បច្ចេកទេសក្នុងការផលិតជាដើម សុទ្ធតែជាមូលហេតុដែលនាំឱ្យចង្វាក់ផលិតកម្មមានការថយចុះ និងមិនអាចផ្គត់ផ្គង់តាមតម្រូវការជាក់ស្ដែង។[225] ដូច្នេះហើយ ការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់វិស័យកសិកម្ម ការបណ្ដុះបណ្ដាលបន្ថែម ក៏ដូចជាគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ពិតជាមានសារៈសំខាន់ដើម្បីលើកស្ទួយវិស័យកសិកម្ម និងលើកកម្ពស់ជីវភាពរបស់ប្រជាកសិករកម្ពុជា។

លក្ខណៈតូចចង្អៀតនៃវិស័យស្នូលសម្រាប់ការទ្រទ្រង់សេដ្ឋកិច្ច នាំឱ្យកម្ពុជាងាយប្រឈមនឹងផលជះពីការថយចុះនៃតម្រូវការទីផ្សារពិភពលោក។ នេះសរបញ្ជាក់ឱ្យឃើញពីសារៈសំខាន់នៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ការបង្កើនកម្លាំងផលិតកម្មក្នុងស្រុក ក្នុងការធានាដល់និរន្តភាពនៃកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជាផ្ទាល់។

---

[223] World Bank, *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩] (World Bank, 2020), 20។

[224] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ ២០២២* (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ មីនា, ២០២២), ១០០។

[225] ដដែល។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

លំហូរនៃគម្រោងវិនិយោគដោយផ្ទាល់ពីបរទេសជាពិសេសទៅលើ គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ បានចូលរួមលើកស្ទួយសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារយ៉ាងខ្លាំងក្លា។ តាមរយៈការបង្កើតការងារធ្វើដល់ប្រជាពលរដ្ឋ បង្កើតប្រាក់ចំណូលគ្រួសារ និងបង្កើតប្រាក់ចំណូលសម្រាប់ជាតិ។

សម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃស្ថេរភាពនយោបាយ គោលនយោបាយគាំទ្រការវិនិយោគរបស់រាជរដ្ឋាភិបាល កម្លាំងពលកម្មគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ដល់ការវិនិយោគ។ កត្តាខាងលើ បង្កើតបានជាបរិយាកាសវិនិយោគដ៏ល្អប្រសើរមួយក្នុងការទាក់ទាញវិនិយោគិនពីបរទេស។ មិនតែប៉ុណ្ណោះ កម្ពុជាទទួលបានអាទិភាពពីប្រព័ន្ធអនុគ្រោះពន្ធ និងពន្ធគយពីបណ្ដាប្រទេសមហាអំណាច ដែលបានក្លាយជាមូលហេតុចម្បងក្នុងការទាក់ទាញការវិនិយោគមកពីបណ្ដាប្រទេសដូចជាមកពីប្រទេសចិន កូរ៉េ វៀតណាម សិង្ហបុរី ជប៉ុន ជាអាទិ៍។ បើទោះបីជាបរិយាកាសវិនិយោគមានភាពប្រសើរហើយក្ដី ការវិនិយោគក៏ពុំអាចដំណើរការបានរលូននោះដែរ ប្រសិនបើគ្មានបទដ្ឋានគតិយុត្តសម្រាប់គាំពារ និងគ្រប់គ្រងការវិនិយោគ។ ហេតុដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវច្បាប់ថ្មីៗជាច្រើន រួមមាន ច្បាប់វិនិយោគ ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ធុរកិច្ច ច្បាប់សំណង់ និង ច្បាប់ស្ដីពីទូរគមនាគន៍ដើម្បីធានាដល់តម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងសម្រាប់គ្រប់គ្រងគម្រោងវិនិយោគ។

ការពឹងផ្អែកខ្លាំងទៅលើវិស័យស្នូលទាំងបួនរួមមាន វិស័យកសិកម្ម វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង វិស័យទេសចរណ៍ និងវិស័យសំណង់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិទាំងមូល បណ្ដាលឱ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈទន់ខ្សោយ និងងាយរងគ្រោះពីបម្រែបម្រួលនៃលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ និងតម្រូវការទីផ្សារពិភពលោក។ ជាក់ស្ដែងភាពទន់ខ្សោយនេះបានស្ដែងចេញយ៉ាងច្បាស់តាមរយៈឥទ្ធិពលនៃវិបត្តិកូវីដ-១៩ ទៅលើវិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង និងវិស័យសំណង់។ ហេតុនេះហើយ កម្ពុជាត្រូវចាប់ផ្ដើមស្ដារសមត្ថភាពរបស់ខ្លួនបន្ថែមទៀត តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ជំរុញការអភិវឌ្ឍលើវិស័យដទៃទៀត ជៀងវាងការពឹងពាក់ទាំងស្រុងទៅលើតែវិស័យចម្បងទាំងបួនដែលបានរៀបរាប់ខាងលើ។

# អនុសាសន៍

# អនុសាសន៍

រាជរដ្ឋាភិបាលកម្ពុជាគប្បីពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែម ដើម្បីអាចទាក់ទាញការវិនិយោគកាន់តែច្រើន តាមរយៈ ការអភិវឌ្ឍធនធានមនុស្ស ការបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីសម្រាប់បំពេញបន្ថែមលើច្បាប់វិនិយោគថ្មី និង ការពិពិធកម្មសេដ្ឋកិច្ច។

រាជរដ្ឋាភិបាលគួរដាក់ចេញគោលនយោបាយ និងយន្តការអនុវត្តបន្ថែម ទាក់ទងនឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញទន់ដល់យុវជនវ័យក្មេង ដែលជាសរសៃឈាមទ្រូងជាតិ។ ការអភិវឌ្ឍធនធានមនុស្សគឺជាកាតាលីករយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ជាក់ស្តែង កម្លាំងចូលរួមពលកម្មនៅកម្ពុជាមានលក្ខណៈវ័យក្មេង ប៉ុន្តែខ្វះខាតពលករជំនាញ និងអ្នកចេះដឹង។ ជាហេតុនាំឱ្យវិស័យធំៗដែលស្រូបយកកម្លាំងពលកម្មនៅកម្ពុជាច្រើនតែជាប្រភេទឧស្សាហកម្មអតិពលកម្ម។ ដើម្បីអភិវឌ្ឍពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មជំនាញ កម្ពុជាត្រូវការកម្លាំងពលកម្មដែលមានចំណេះដឹង និងចំណេះជំនាញច្បាស់លាស់។

រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីបំពេញបន្ថែមលើច្បាប់វិនិយោគថ្មីព្រោះច្បាប់វិនិយោគថ្មី ទើបតែអនុម័តឡើងនៅឆ្នាំ ២០២១ ដោយគ្មានអនុក្រឹត្យថ្មី និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗមកបំពេញបន្ថែមលើច្បាប់វិនិយោគថ្មីនេះទេ។ ដូច្នេះ បទដ្ឋានគតិយុត្តពិតជាមានភាពចាំបាច់សម្រាប់បម្រើដល់វិស័យវិនិយោគនៅកម្ពុជា។

រាជរដ្ឋាភិបាលគប្បីធ្វើពិពិធកម្មសេដ្ឋកិច្ច និងជៀសវាងការពឹងផ្អែកទាំងស្រុងទៅលើវិស័យស្នូលទាំង ៤ រួមមាន វិស័យកសិកម្ម វិស័យកាត់ដេរ និងសម្លៀកបំពាក់ វិស័យទេសចរណ៍ និងសំណង់។ ការយកចិត្តទុកដាក់បន្ថែមទៅលើវិស័យផ្សេងៗទៀត ជាពិសេសឧស្សាហកម្មកមន្តសាល និងកសិឧស្សាហកម្ម តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានឧស្សាហកម្មឱ្យកាន់តែប្រសើរ ទើបអាចបង្កើតផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងបង្កើនផលិតកម្មក្នុងស្រុក។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


ច្បាប់ភូមិបាល. លេខ នស/រកម/០៨០១/១៤. ៣០ សីហា ២០០១។

ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់. លេខ នស/រកម/១១១៩/០១៦. ០២ វិច្ឆិកា ២០១៩។

ច្បាប់ស្តីពីការប្រកួតប្រជែង. លេខ នស/រកម/១០២១/០១៣. ០៥ តុលា ២០២១។

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងប្រទេសជាសមាជិក អាស៊ាន និង ប្រទេសជប៉ុន. លេខ នស/រកម/១០០៩/០១៩. ២២ តុលា ២០០៩។

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខណ្ឌសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន និង សាធារណរដ្ឋកូរ៉េ. លេខ នស/រកម/១២០៧/០៣៤. ២៧ ធ្នូ ២០០៧។

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន–អូស្ត្រាលី–ណូវែលហ្សេឡង់. លេខ នស/រកម/១០១០/០១៦. ២៦ តុលា ២០១០។

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន. លេខ នស/រកម/១០២១/០០៩. ០៥ តុលា ២០២១។

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់. លេខ នស/រកម/១០២១/០១០. ០៥ តុលា ២០២១។

ច្បាប់ស្តីពីក្ស័យធន. លេខ នស/រកម/១២០៧/០៣១. ០៨ ធ្នូ ២០០៧។

ច្បាប់ស្តីពីទូរគមនាគមន៍. លេខ នស/រកម/១២១៥/០១៧. ១៧ ធ្នូ ២០១៥។

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម. នស/រកម/០១០៣/០០៥. ២២ មករា ២០០៣។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក. លេខ នស/រកម/១១១៩/០១៧. ០២ វិច្ឆិកា ២០១៩។

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់. លេខ នស/រកម/០២០២/០០៦. ០៧ កុម្ភៈ ២០០២។

ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ. លេខ នស/រកម/០១១៤/០០៦. ២២ មករា ២០១៤។

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា. លេខ នស/រកម/១០២១/០១៤. ១៥ តុលា ២០២១។

ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា. លេខ នស/រកម/០៣០៣/០០៩. ២៤ មីនា ២០០៣។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម. លេខ នស/រកម/០៦០៥/០១៩. ១៩ មិថុនា ២០០៥។

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល. លេខ នស/រកម/០៣០៣/០០៨. ០៥ មីនា ២០០៣។

ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩. ០២ វិច្ឆិកា ២០១៩។

ប្រកាសរបស់ក្រសួងពាណិជ្ជកម្មស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក. លេខ ២៩០ ព.ណ ចបពប្រក. ៩ តុលា ២០២០។

ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់. លេខ ០១៣ ដនសប្រក./នី.ក. ២០ មករា ២០២២។

ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែល បានសាងសង់រួចមុនពេលច្បាប់សំណង់, លេខ ១៧៧ ដនស/ប្រក., ០៦ ធ្នូ ២០១៩, ប្រការ១៣។

ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ស្តីពីបែបបទនៃការងារត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់គ្រឿងបង្គុំសំណង់. លេខ ១០៩ ដនស/ប្រ.ក/នី.ក. ២២ វិច្ឆិកា ២០២១។

ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ. លេខ ៧០១ សហវ.ប្រក. ១៤ សីហា ២០២០។

ប្រកាសអន្តរក្រសួងរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពលស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា. លេខ ០៩៨ ពណ.អរង.ប្រក. ០៩ មីនា ២០១៦។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា. ២១ កញ្ញា ១៩៩៣។

សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីការពិគ្រោះយោបល់សាធារណៈ លើគម្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីពីប្រភពបណ្តាញជាតិ សម្រាប់លក់ឱ្យអ្នកកាន់អាជ្ញាបណ្ណដែលទិញអគ្គិសនីពីអគ្គិសនីកម្ពុជា និងពីអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន សម្រាប់ឆ្នាំ២០២២. លេខ ១៣២.សណ.២១ អអក, ១០ កញ្ញា ២០២១។

អនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស. លេខ ១៤៨ អនក្រ.បក. ២៩ ធ្នូ ២០០៥។

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ. លេខ ២៣ អនក្រ.បក. ១៦ កុម្ភៈ ២០២១។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា. លេខ ៦០ អនក្រ.បក. ០៥ មេសា ២០១៦។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត. លេខ ១២០ អនក្រ.បក. ២០ មិថុនា ២០២២។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា. លេខ ១១១ អនក្រ.បក. ២៧ កញ្ញា ២០០៥។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់វិនិយោគ. លេខ ១១១ អនក្រ.បក. ២៧ កញ្ញា ២០០៥។

អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យនិងការបញ្ជាក់សំណង់. លេខ ២២៥ អនក្រ.បក. ៣០ ធ្នូ ២០២០។

អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់. លេខ ២២៦ អនក្រ.បក. ៣០ ធ្នូ ២០២០។

អនុក្រឹត្យស្ដីពីលិខិតអនុញ្ញាតសាងសង់. លេខ ២២៤ អនក្រ.បក. ៣០ ធ្នូ ២០២០។

**សៀវភៅ និងឯកសារជាខេមរភាសា**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. *របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ២០២២.* ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០២២។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល. *គោលនយោបាយ, យុទ្ធសាស្ត្រ, និងផែនការជាតិ ស្តីពីប្រសិទ្ធភាពថាមពលអគ្គសនីនៅក្នុងប្រទេសកម្ពុជា.* រដ្ឋាភិបាល. ១៦ ឧសភា ២០១៣។

ក្រុមធនាគារពិភពលោក. *បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ ប្រទេសកម្ពុជាបានកើនឡើងនូវខ្សែសង្វាក់ផលិតកម្ម.* ទីក្រុងវ៉ាស៊ីនតោន៖ ធនាគារពិភពលោក. ២០១៨។

ជា, មុយគីម និង ចាន់ ផល្លីកា. *កម្ពុជា និងប្រព័ន្ធអនុគ្រោះពន្ធ EBA៖ តើមានផលប៉ះពាល់បែបណាខ្លះ?.* ភ្នំពេញ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា. ២០២០។

រាជរដ្ឋាភិបាលកម្ពុជា. *គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥.* ភ្នំពេញ៖ គណៈរដ្ឋមន្ត្រី, ២០១៥។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ. *ជំរឿនទូទៅប្រជាជនព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របាយការណ៍ស្តីពីលទ្ធផលចុងក្រោយ.* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ. ២០១៩។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ. *របាយការណ៍ស្តីពីអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩.* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ. ២០១៩។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ. *របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០២០.* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ។

ហ៊ុន, សែន. សារលិខិតរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសទិវាទេសចរណ៍ពិភពលោកក្រោមប្រធានបទ «និរន្តរភាពទេសចរណ៍ ជាយន្តការសម្រាប់ការអភិវឌ្ឍ». ២៧ កញ្ញា ២០១៧។

ហេង, សុភី. *សេដ្ឋកិច្ច និងទេសចរណ៍កម្ពុជាក្នុងដំណាក់កាលជម្ងឺកូវីដ១៩.* ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា. ២០២០។

អង្គការពលកម្មអន្តរជាតិ. *ការស្រាវជ្រាវផ្តោតលើសកម្មភាពអំពីសមភាពយេនឌ័រ និងលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករនិយោជិតរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា* ( ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក. ២០១២។

អង្គការពលកម្មអន្តរជាតិ. *ការស្រាវជ្រាវផ្តោតលើសកម្មភាពអំពីសមភាពយេនឌ័រ និងលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់កម្មករនិយោជិតរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា.* ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក. ២០១២។

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ. *ក្របខណ្ឌ និងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥.* រដ្ឋាភិបាល. ២០២១។

## សៀវភៅ និងឯកសារជាភាសាបរទេស


Arnold, Dennis. *Cambodia's Garment Sector in Transformation: External Shocks, Political Space, and Supplier Consolidation* [បំលាស់ប្តូរនៃវិស័យកាត់ដេរនៅកម្ពុជា៖ ឥទ្ធិពលខាងក្រៅ បញ្ហានយោបាយ និង ការប្រកួតប្រជែងរវាងអ្នកផ្គត់ផ្គង់]. CNV International, 2021។

Asian Development Bank, *Cambodia: Diversifying Beyond Garments and Tourism* [កម្ពុជា ៖ ការធ្វើពិពិធកម្មលើសពីវិស័យកាត់ដេរ និងទេសចរណ៍]. Phillipines: Asian Development Bank. 2014។

Chan, Sophal និង Sothea Oum. *Impact of garment and textile trade preferences on livelihoods in Cambodia* [ផលវិបាកនៃវិស័យកាត់ដេរ និងវាយនភណ្ឌលើជីវភាពរស់នៅនៅកម្ពុជា]. Oxfam America Research Backgrounders Series. 2011។

Edge, Abby និង Sheng Lu. *How will EU trade curb affect Cambodia's apparel industry?* [ការតភ្ជាប់កិច្ចសន្ទនាសង្គមក្នុងវិស័យកាត់ដេរ៖ កម្ពុជា]. JustStyle. 2020។

Eurocham. *Business Opportunities in Cambodia: Investment Information* [ឱកាសពាណិជ្ជកម្មនៅកម្ពុជា៖ ព័ត៌មានសម្រាប់ការវិនិយោគ]. Phnom Penh: Eurocham។

Hem, Sochet. *Foreign Investment in Agriculture in Cambodia: A survey of recent trends* [ការវិនិយោគពីបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា៖ ការពិនិត្យលើនិន្នាការថ្មីៗ]. Trade Knowledge Network. 2012។

International Labor Organization. *What explains strong export and weak employment figures in the Cambodian garment sector?* [តើអ្វីជាមូលហេតុនៃការនាំចេញច្រើន និងអត្រាពលកម្មទាបក្នុងវិស័យកាត់ដេរនៅកម្ពុជា ?]. Cambodia Garment and Footwear Sector Bulletin. 2017។

Nuon, Veasna. *Mapping Social Dialogue in Apparel: Cambodia* [ការតភ្ជាប់កិច្ចសន្ទនាសង្គមក្នុងវិស័យកាត់ដេរ៖ កម្ពុជា]. ILR New Conversations Project. 2021។

Saing, Chan Hang, Hem Socheth, Ouch Chandarany, and Pon Dorina. *Foreign Investment in Agriculture in Cambodia* [ការវិនិយោគពីបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា]. Cambodia's Leading Independent Development Policy Research Institute. 2012។

Sar, Senera. *A Snapshot on Investment Climate & Regulatory Framework for Investment in Cambodia* [រូបភាពនៃបរិយាកាសវិនិយោគ និងបទដ្ឋានគតិយុត្តគ្រប់គ្រងការវិនិយោគនៅកម្ពុជា]. Phnom Penh. 2019។

Seong, Rith, L. Cuyvers និង S. Sok. *Do Institutions Matter for Foreign Direct Investment in Cambodia* [តើស្ថាប័នមានសារៈសំខាន់ចំពោះការវិនិយោគដោយផ្ទាល់នៅកម្ពុជាឬទេ]. Centre for ASEAN Studies. 2017។

UNCTAD. *World Investment Report 2021.* [របាយការណ៍វិនិយោគពិភពលោកឆ្នាំ២០២១]. New York: United Nations Publications. 2021។

United Nations Cambodia. *Cambodia Common Country Analysis: Towards an Inclusive, Equitable and Sustainable Recovery* [ការវិភាគជារួមលើកម្ពុជា៖ ឆ្ពោះទៅកាន់ការស្តារសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន សមធម៌ និងនិរន្តរភាព]. Phnom Penh: United Nations Country Team Cambodia. 2021។

World Bank Group. *Enhancing Export Competitiveness: The Key to Cambodia's Future Economic Success* [ការលើកកម្ពស់ការប្រកួតប្រជែងក្នុងការនាំចេញ៖ គន្លឹះនៃភាពជោគជ័យរបស់សេដ្ឋកិច្ចកម្ពុជានាពេលអនាគត]. World Bank. 2016។

World Bank. *Cambodia Economic Update: Cambodia in the Time of Covid-19* [បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ កម្ពុជាក្នុងសម័យកូវីដ-១៩]. World Bank. 2020។

## ឯកសារជាខេមរភាសាដកស្រង់ពីអ៊ីនធឺណិត

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ពិតជាធ្វើឲ្យវិស័យនេះ មាននិរន្តរភាព បន្តរីកចម្រើនទៅមុខទៀត, អាចរកបាននៅ https://bit.ly/3SsPT6n (ទស្សនាចុងក្រោយថ្ងៃទី២៩ កក្កដា ២០២២)។

ក្រសួងសាធារណការ និងដឹកជញ្ជូន. *ហេដ្ឋារចនាសម្ព័ន្ធ៖ ផ្លូវល្បឿនលឿន,* អាចរកបាននៅ www.mpwt.gov.kh/_kh/public-works/expressways (ទស្សនាចុងក្រោយថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០២២)។

ក្រសួងអភិវឌ្ឍន៍ជនបទ. គម្រោងកែលម្អផ្លូវជនបទជំហានទី៣. អាចរកបាននៅ https://bit.ly/3BHa76p (ទស្សនាចុងក្រោយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)។

ខ្មែរថាមស៍. កម្ពុជាទាក់ទាញការវិនិយោគចំនួន ៤.៣៥ ពាន់លានដុល្លារក្នុងឆ្នាំ២០២១. អាចរកបាននៅ https://bit.ly/3p14gBa (ចូលទស្សនាថ្ងៃទី១៧ ឧសភា ២០២២)។

ធនាគារពិភពលោក. កម្ពុជារក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នា. អាចរកបាននៅ https://www.worldbank.org/km/country/cambodia/publication/Cambodia-Systematic-Country-Diagnostics (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២២)។

ប្រាជ្ញ, សុវណ្ណរ៉ា. បទយកការណ៍! ក្រោមប្រព័ន្ធអនុគ្រោះពន្ធ GSP របស់អង់គ្លេស កម្ពុជានឹងទទួលបានប្រយោជន៍ច្រើនក្នុងការនាំចេញ. ភ្នំពេញ៖ ខ្មែរប៉ុស្តិ៍, ២០២០. អាចរកបានៅ https://khmerpostasia.com/archives/61802 (ទស្សនាថ្ងៃទី១១ មិថុនា ២០២២)។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ. ការវិនិយោគ (២០២១). អាចរកបាននៅ https://opendevelopmentcambodia.net/km/topics/investment/ (ទស្សនាចុងក្រោយថ្ងៃទី ១៦ ឧសភា ២០២២)។

## ឯកសារជាភាសាបរទេសដកស្រង់ពីអ៊ីនធឺណិត

Asian Development Bank. ADB's New 5-Year Country Strategy Supports Economic Diversification. Inclusive Growth in Cambodia [យុទ្ធសាស្ត្រប្រទេស រយៈពេល ៥ ឆ្នាំ របស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការគាំទ្រការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកំណើន]. អាចរកបាននៅ

https://www.adb.org/news/adbs-new-5-year-country-strategy-supports-economic-diversification-inclusive-growth-cambodia (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២២)។

Soth, Koemsoeun. Skilled workforce needed for business expansion [តម្រូវការពលកម្មជំនាញដើម្បីពង្រីកធុរកិច្ច]. Khmer Times. 2022. អាចរកបាននៅ https://www.khmertimeskh.com/501034697/skilled-workforce-needed-for-business-expansion/ (ទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**គណៈកម្មាធិការវិនិយោគកម្ពុជា**

## ពាក្យសុំវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា

**I- របនាសម្ព័ន្ធក្រុមហ៊ុន** ÷

***ក. ពត៌មានទូទៅ***÷

- ឈ្មោះក្រុមហ៊ុន : ..................................................................................................
- អាស័យដ្ឋាន : - ទីស្នាក់ការក្រុមហ៊ុន : ..........................................................................
  ..........................................................................
  - ក្រុមហ៊ុនមេឈ្មោះ : ..........................................................................
  អាស័យដ្ឋាន : ..........................................................................
  Tel: ............................................ Fax: ...............................................
  Website: .................................... E-mail: ..........................................
- ទ្រង់ទ្រាយក្រុមហ៊ុន : (***សូមគូស ✓ ក្នុងប្រអប់***)
  ☐ ក្រុមហ៊ុនមូលធន (Corporation) ☐ ក្រុមហ៊ុនសហកម្មសិទ្ធិ (Partnership)
  ☐ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស

  ***កំណត់សម្គាល់***: ក្រុមហ៊ុនមូលធនរួមមាន : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Single Limited Company)
- ទុនចុះបញ្ជី : ................................................ បរទេស : ............ ក្នុងស្រុក :...............
- លិខិតបញ្ជាក់ប្រាក់តម្កល់នៅធនាគារ ២៥% លេខ : ......................

***ខ. សមាសភាពក្រុមហ៊ុន***

**ម្ចាស់ភាគហ៊ុន**

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | អត្រាភាគហ៊ុន% |
|---|---|---|---|---|
| ១. ..........................<br>២. ..........................<br>៣. ..........................<br>៤. .......................... | | | | |

**សមាសភាពក្រុមប្រឹក្សាភិបាល (រួមទាំងតតីយជន)**

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | តួនាទីក្នុងក្រុមហ៊ុន | អ្នកដែលមានសិទ្ធិ ចុះហត្ថលេខា សម្រាប់កិច្ចការ |
|---|---|---|---|---|---|
| ១. ...........................<br>២. ...........................<br>៣. ...........................<br>៤. ........................... | | | | | |

## II- ពាក្យស្នើសុំវិនិយោគ :

### ក. ព័ត៌មានទូទៅ

- មុខសញ្ញាវិនិយោគ : ..........................................................................................................
- វិស័យវិនិយោគ : (*សូមគូស ✓ ក្នុងប្រអប់*)

  ☐ កសិកម្ម-កសិ-ឧស្សាហកម្ម ☐ សំណង់ស៊ីវិល ☐ ថាមពល ☐ ហិរញ្ញវត្ថុ ☐ ឧស្សាហកម្ម ☐ ធនធានរ៉ែ

  ☐ ទេសចរណ៍ ☐ ដឹកជញ្ជូន ☐ ទូរគមនាគមន៍ ☐ ទឹកស្អាត ☐ តំបន់ឧស្សាហកម្ម ☐ ផ្សេងៗ
- អ្នកដាក់ពាក្យសុំវិនិយោគ :
  - ឈ្មោះ ............................................ អាស័យដ្ឋាន :.......................................................
  - តួនាទីក្នុងក្រុមហ៊ុន :............................ Tel : .......................... Fax :.........................
  - លិខិតប្រគល់សិទ្ធិ (*បើសិនមិនមានតួនាទីក្នុងក្រុមហ៊ុន*):លេខ............... ចុះថ្ងៃទី..... ខែ.......ឆ្នាំ......
- ទុនវិនិយោគសរុប :......................................... ក្នុងនោះទុនលើ :
  - ដីធ្លី (ទំហំ ម²) : ............................ តម្លៃ : .............................. USD
  - សំណង់អាគារ/រៀបចំការដ្ឋាន :............ ម² តម្លៃ......................USD ☐អាគារមានស្រាប់ ☐អាគារថ្មី
  - សម្ភារៈបរិក្ខារផលិតកម្ម (គ្រឿងចក្រ-គ្រឿងម៉ាស៊ីនផលិតកម្ម-សម្ភារៈបរិក្ខារផ្សេងៗ) តម្លៃ (USD): .................................................(មានបញ្ជីជូនភ្ជាប់ តាមទិរង់ដូចមានចែងក្នុងឧបសម្ព័ន្ធ)
  - ការិយាល័យតម្លៃ (USD) : .................................
  - ផ្សេងៗតម្លៃ (USD):..........................................
- ប្រភពទុនវិនិយោគ : ទុនផ្ទាល់ :.................................. ឥណទានធនាគាររយៈពេលវែង : ..................

  ឥណទានធនាគាររយៈពេលខ្លី :..............................
- ទីតាំងវិនិយោគ : ដីឡូត៍លេខ................ផ្លូវលេខ ............... ភូមិ.......................ឃុំ/សង្កាត់...............

  ស្រុក/ខណ្ឌ:................ខេត្ត/ក្រុង :............ ទំហំ :....................ម²
- កម្មវិធីអនុវត្តគម្រោង :
  - ចាប់ផ្តើមសាងសង់:.............................. ព្យាករណ៍បញ្ចប់ការសាងសង់:..............................
  - ពេលបំពាក់គ្រឿងម៉ាស៊ីន: ...................... ចាប់ផ្តើមដំណើរការផលិតកម្ម:..............................
- ពត៌មានស្តីពីផលិតផល :

| ប្រភេទផលិតផល | ឯកតា | សមត្ថភាពផលិតប្រចាំឆ្នាំ | | | | ទីផ្សារ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំដំបូង | | ពេញផលិតកម្ម | | | |
| | | បរិមាណ | តម្លៃ | បរិមាណ | តម្លៃ | ក្នុងស្រុក គិតជា% | នាំចេញ គិតជា % |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

- តម្រូវការពលកម្ម

| ប្រភេទពលកម្ម | ពេលចាប់ផ្តើម | | ពេលពេញសមត្ថភាព | |
|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស |
| - អ្នកគ្រប់គ្រង | | | | |
| - វិស្វករ | | | | |
| - អ្នកបច្ចេកទេស | | | | |
| - ទីប្រឹក្សា | | | | |
| - បុគ្គលិកការិយាល័យ | | | | |
| - បុគ្គលិកជំនាញ | | | | |
| - បុគ្គលិកគ្មានជំនាញ | | | | |
| សរុប | | | | |

- តម្រូវការធាតុចូលផលិតកម្ម (វត្ថុធាតុដើម) ប្រចាំឆ្នាំ: *បំពេញតាមទម្រង់ដូចមានថែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ*
- តម្រូវការថាមពល និងទឹក :
  - ធ្យូងថ្ម ឬអុសប្រចាំឆ្នាំ : .................... ម៣/ ឆ្នាំ, ឧស្ម័ន : .................................... តោន/ ឆ្នាំ
  - ប្រេងឥន្ធនៈ : ................................ តោន ឬលីត្រ/ ឆ្នាំ
  - អគ្គិសនី (អនុភាពតម្លើង) : ................ MW តម្រូវការប្រចាំឆ្នាំ : ............................ KWH
  - ប្រើប្រាស់ទឹក :................................ ម៣/ ឆ្នាំ,

***ខ- <u>ការជ្រើសរើសរវាង :</u>*** ☐ ការលើកលែងពន្ធលើប្រាក់ចំណេញ ☐ រំលោះពិសេស

☐ ដើម្បីទទួលបានតែការធានាលើការវិនិយោគ (មិនទាមទារការលើកទឹកចិត្ត)

*(ក្នុងចំណោមជម្រើសទាំងបីនេះ វិនិយោគិនមានសិទ្ធិទទួលបានតែមួយប៉ុណ្ណោះ)*

***គ- <u>ពត៌មានស្តីពីបរិស្ថាន :</u>***

- រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេច ចេញ- ចូល ទីតាំងវិនិយោគ:

.........................................................................................................................

.........................................................................................................................

..............................................................................................................................

..............................................................................................................................

ប៉ាន់ស្មានបរិមាណ :

សំណល់រាវ :.............................$m^3$/ខែ សំណល់រឹង :........................ម$^{៣}$ ឬតោន/ខែ

ឧស្ម័នដែលត្រូវបញ្ចេញ : .................................................................../day

- តារាងប៉ាន់ស្មាននៃកំហាប់ក្នុង :

*ដំណើរការបញ្ចេញទឹកស្អុយ*

- pH :................................................ - អាម៉ូញាក់ Ammonia ($NH_3$) ................................
- នីត្រាតអាស៊ូត Nitrate Nitrogen.............. - លោហៈធ្ងន់ Heavy Metal..................................
- ផេណុល Phenol ($C_6H_5OH$)................... - ប្រេង និងខ្លាញ់ Oil and Grease...........................
- ភាពល្អក់ Turbidity .............................. - ភាពចម្លងអគ្គិសនី Conductivity ............................
- ចំនួនសរុបនៃសារធាតុរឹងដែលរលាយក្នុងទឹក...........................................................................
- ចំនួនសរុបនៃសារធាតុរឹងដែលរងកករចុះទៅក្នុងទឹក......................................................................

ការបំភាយភាគល្អិតតូចៗនៃឧស្ម័នក្នុងខ្យល់

- កាបូនម៉ូណូអុកស៊ីត Carbon mono-oxide........... - អាស៊ូតឌីអុកស៊ីត Nitrogen Dioxide................
- អុកស៊ីតស៊ុលផួរិច Sulfur Oxide ....................... - អូស៊ូន Ozone...........................................
- សំណរ Lead..................................................

- ទីតាំងដែលប្រើសម្រាប់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ និងការបញ្ចេញឧស្ម័ន

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

- ប្រភពដែលមានសម្លេង និងភាពរំញ័រខ្ពស់កើនឡើង

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

- ទំហំផ្ទៃដីដែលនឹងគ្របដណ្តប់ សម្រាប់ករណីចាក់ដីបំពេញ - ការឈូសឆាយ និងការរានដីថ្មី

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

- ស្ថានភាពស្នាក់នៅរបស់បុគ្គលិក - កម្មករ

- ផ្គត់ផ្គង់ទឹកស្អាត : ..................................................................................................
- សុខភាព - សុវត្ថិភាព :..................................................................................................
- អនាម័យ :..................................................................................................
- ការគ្រប់គ្រងសំណល់រឹង : ..................................................................................................

***ឃ- ពត៌មានស្តីពីពន្ធដារ***

បំពេញតាមទម្រង់បែបបទ (Form) ដូចមានឧបសម្ព័ន្ធជូនភ្ជាប់

**III- ការធានា : ក្នុងនាមម្ចាស់គម្រោងសូមធានាអះអាងថា**

- គម្រោងនេះមិនស្ថិតក្នុងបញ្ជីគម្រោងហាមឃាត់ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគទេ។
- ពត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវ ដោយមិនមានចេតនាក្លែងបន្លំឡើយ។

ធ្វើនៅ .......................ថ្ងៃទី ........ខែ ..........ឆ្នាំ ............

ហត្ថលេខា

## **ឧបសម្ព័ន្ធទី ១**

តារាងតម្រូវការសម្ភារៈបរិក្ខារផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.....................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកតា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | **សរុប** | | | | | | |

**<u>ឧបសម្ព័ន្ធទី ២</u>**

តារាងតម្រូវការធាតុចូលផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.....................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកតា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | **សរុប** | | | | | | |

## ឧបសម្ព័ន្ធទី ១

## បញ្ជីគម្រោងហាមឃាត់ (សេចក្តីព្រាង)[1]

- សកម្មភាព ឬវិស័យដែលច្បាប់ហាមឃាត់.............................................................................
- ការផលិត ឬការកែច្នៃវត្ថុដែលពាក់ព័ន្ធដល់កិច្ចការវប្បធម៌ .......................................................
- ការផលិត ឬផលិតកម្ម ឈើអារ ឈើចំណិត ក្តារបន្ទះ ឬផលិតអំពីឈើ ដោយប្រើឈើមូលក្នុងស្រុកជាវត្ថុធាតុដើម
  ...........................................................................................................................
- ផលិតកម្មនៃ DBSA..........................................................................................................
- ការផលិត ឬផលិតកម្មគ្រឿងគីមីពុលដែលមានប៉ះពាល់ទៅលើសុខភាពសហគមន៍ ឬមានប៉ះពាល់ចំពោះបរិស្ថាន
  ...........................................................................................................................
- ការផលិត ឬផលិតកម្មគ្រឿងគីមីពុល ឬការប្រើប្រាស់សមាសធាតុពុល........................................
- ការផលិតសារធាតុ Psychotropic .......................................................................................
- ការផលិតថ្នាំញៀនណាកូទីន................................................................................................
- ផលិតកម្មអាវុធ ឬគ្រាប់រំសេវ..............................................................................................
- ការផលិតគ្រឿងផ្ទុះ ឬកាំជ្រួច...............................................................................................
- ផលិតកម្មទំនិញទាក់ទងទៅនឹងការការពារ ឬសន្តិសុខជាតិ.........................................................
- រាល់សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ...................................................................................
- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ............................................................................................
- ហាងទំនិញរួចពន្ធ ..............................................................................................................
- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល និងកន្លែងធ្វើសរសៃផ្សេងៗទៀត ដែលស្ថិតនៅក្រៅបរិវេណសណ្ឋាគារខ្នាតអន្តរជាតិ.............................................................................................................
- មជ្ឈមណ្ឌលពាណិជ្ជកម្ម.....................................................................................................
- សកម្មភាពដែលទាក់ទងនឹងសារពត៌មាន និងប្រព័ន្ធឃោសនា (វិទ្យុ ទូរទស្សន៍ សារពត៌មាន) .............
- លក់រាយ និងលក់ដុំ ...........................................................................................................
- សេវាផ្នែកជំនាញ ...............................................................................................................

[1] *បញ្ជីគម្រោងហាមឃាត់នេះ នឹងយកតាមអនុក្រឹត្យថ្មី ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។*